# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៧-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/១០០៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ដៃគូសហប្រតិបត្តិការអន្តរជាតិ ចំនួន ១៨ រូប ៩៣៤៨

០១-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១០ ស្ដីពី ការបញ្ចូលឯកឧត្ដម **ថៃ នរៈសត្យា** ទៅក្នុងឋានន្តរស័ក្តិ ឧត្ដមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខណ្ឌ មន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ៩៣៤៩

០៥-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះឯកឧត្ដម **សេង យូអ៊ាន់** ៩៣៥០

០៥-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ វិទ្យាស្ថានក្រុងអង្គរ ខេត្តកំពង់ធំ ចំនួន ១៥ រូប ៩៣៥១

០៦-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១៨ ស្ដីពី ការតែងតាំងឯកឧត្ដម **ខៀវ សុគន្ធ** ជាអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជននិង យុវនីតិសម្បទា ៩៣៥២

០៦-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០១៩ ស្ដីពី ការតែងតាំងឯកឧត្ដម **នេត ធារ៉ុម** ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ៩៣៥៣

០៦-១២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១២១២/១០២៣ ស្ដីពី ការកាត់ផ្ទៃដីទំហំ ១៧១ ហិកតា ពីឧទ្យានជាតិកែប នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៣ ៩៣៥៤


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


៣០-១១-២០១២-អនុក្រឹត្យលេខ ២១៧ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៩៣៥៥

០១-១២-២០១២-អនុក្រឹត្យលេខ ២១៨ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១១.៤៩៤,៩៥ ហិកតា ដែលក្នុងនោះ (១) កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣, (២) ពីក្រុមហ៊ុន HLH,(៣) ពីក្រុមហ៊ុន Great Field,(៤) ពីក្រុមហ៊ុន Future Environment, និង (៥) ពីក្រុមហ៊ុន Yee Jia ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវទំហំ ៦.១០១,៨២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៦,៩៩ គ្រួសារ និង ទំហំ ៥.៣៩២,៧៣ ហិកតា រក្សាទុកសម្រាប់ជាដីសាធារណៈរបស់រដ្ឋ និង ស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបាន កាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង ចំនួន ២.៦៩៩ គ្រួសារ លើ ៧.១០៧ ក្បាលដី នូវផ្ទៃដីទំហំ ៦.១០១,៨២ ហិកតា នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ៩៣៥៧

០១-១២-២០១២-អនុក្រឹត្យលេខ ២១៩ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២.២៩៧,០៨ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដែលក្នុងនោះទំហំ ២.១៨២,៨២ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.៣៣៤ គ្រួសារ និង ដីទំហំ ១១៤,២៦ ហិកតា រក្សាទុកសម្រាប់ជាដីសាធារណៈរបស់រដ្ឋ និង ស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ២.៣៣៤ គ្រួសារ លើ ៣.៣៩៩ ក្បាលដី ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅក្នុងស្រុក ឧដុង្គ ខេត្តកំពង់ស្ពឺ ៩៣៦៤

០៣-១២-២០១២-អនុក្រឹត្យលេខ ២២០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគកាត់ដី (១) ទំហំ ៦០៣,៩៧ ហិកតា ចេញពីគម្របព្រៃឈើ ២០០២ និង (២) ទំហំ ១៣២,០៨ ហិកតា ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អាន ម៉ាឌី ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និង គោរពស្នើសុំប្រទានកម្មដីទំហំ ៣៧១,៤៩ ហិកតា ជំនួស សម្បទានសង្គមកិច្ច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប ៦១៥ គ្រួសារ និង ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ចំនួន ១.០៧៦ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ៦១៥ គ្រួសារ លើ ១.០៧៥ ក្បាលដី និង កម្មសិទ្ធិអវិភាគ ០១ ក្បាលដី (ទួលកប់ខ្មោច) នៅឃុំគគីរ និង ឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង ៩៣៧២

២៣-១០-២០១២-អនុក្រឹត្យលេខ **២០២៨** ដល់អនុក្រឹត្យលេខ **២០៥០** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៣៧៩

## III-ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


០៦-១១-២០១២ -ប្រកាសលេខ ១១១០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេអបី អាកសិនថិចស្ដាយ& ក្លូសស៊ីង បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ (កាត់ដេរ,ចាក់) ៩៤០២

០៦-១១-២០១២ -ប្រកាសលេខ ១១១១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជៀនឡី ហ្វ៊ូតវែរ អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ ផលិតស្បែកជើង ៩៤០៦

០៦-១១-២០១២ -ប្រកាសលេខ ១១១២ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេ& ជេ ខាតធើរ (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩៤១០


### ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


១៩-១០-២០១២ -ប្រកាសលេខ ៤៥៦ ប្រក.កសក ស្ដីពី នីតិវិធី និង ការតម្រូវបមាណីយសម្រាប់ការចុះបញ្ជី ថ្នាំ កសិកម្ម ៩៤១៤


### ៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៧៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្លូន ជាន អ៊ីមផត អិចផត & អ៊ិនវេសមេន** ៩៤៥៦

១៩-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៨១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ដារ រស្មី អ៊ិនវេសមេន & ឌីវេឡុបមេន គ្រុប** ៩៤៥៨

២០-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៨៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គិត ម៉ុន ខនស្ត្រាក់ស៊ឹន ប្រដាត់** ៩៤៦០

២០-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៨៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី ស៊ី ឌី ត្រេដ** ៩៤៦២

២០-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៨៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រីន ទ្រី ឡាយហ្វ៍ ត្រេឌីង** ៩៤៦៤

២០-៧-២០១១ -លិខិតបញ្ជាក់លេខ ៤១៨៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រីហ្វេសិនណល ផាតនើរ អ៊ែតវើថាយស៊ីង** ៩៤៦៦

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/១០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដៃគូសហប្រតិបត្តិការ អន្តរជាតិ ចំនួន ១៨រូប ដែលមានស្នាដៃល្អក្នុងការ អនុវត្តគម្រោងកម្មវិធីលើវិស័យពិការភាព ក្នុងឱកាសប្រារព្ធទិវាជនពិការកម្ពុជាលើកទី១៤ និងជនពិការអន្តរជាតិលើកទី៣០ នាថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ អោយកាន់តែប្រសើរឡើង

នូវ

ក-គ្រឿងឥស្សរិយយស ជាតូបការ

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | សយ ស៊ីផុន | ៣- | ឯកឧត្តម | យី យ៉ុន |
| ២- | ឯកឧត្តម | សែម សុខា | | | |

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | រស់ រឿន | ៣- | H.E Mr | MASAFUMI Kuroki |
| ២- | ឯកឧត្តម | ឡៅ សុគន្ធ | ៤- | Mrs | Helen Pitt |

គ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១- | Ms. | Rana Flower | ២- | Her Excellency | Penny Richards |

ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | ឆាយ វណ្ណា | ៤- | លោក | មូល ឈន |
| ២- | លោក | ឡៅ ម៉េង | ៥- | លោក | ម៉ា ចំនួនណាត |
| ៣- | លោក | សាត សុផល | ៦- | លោក | ស៊ឹម សឿន |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

- ឯកឧត្តម យី ទាសនា

ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ជួរ រតនៈ | ២- | លោក | ទី សន |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នសរា.១៤១១.១០០៧

ចម្លងចេញពីច្បាប់ដើម ៧៧ ច.ល
ដើម្បីចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
សយ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះក្រមលេខ នស / រកម/ ០១៩៦ /០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦ /០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចូលឯកឧត្តម **ថៃ នរៈសត្យា** ទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ភរល-១៤១៤-១០៤០

លេខៈ ... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១២
អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋាភិបាល
... សុខា

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២*

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម សេង យូអ៊ាន់

ដែលបានខិតខំបំពេញភារកិច្ចជូនជាតិមាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.១២១២.១០១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២

លេខ:៩៨០ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]ទីស្តីការគណៈរដ្ឋមន្ត្រី [illegible]រាជរដ្ឋាភិបាល

[illegible]ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

ថ្នាក់ដឹកនាំវិទ្យាស្ថានក្រុងអង្គរ ខេត្តកំពង់ធំ ចំនួន ១៥រូប ដែលបានលះបង់កំលាំងកាយចិត្ត
និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

- លោក តើត រ័ត្ន

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោក ខៀវ សុខនី
២- លោក តៅ ប្រាជ្ញ
៣- លោក ពូធ សាវ៉ាន
៤- លោក កុយ កុសល
៥- លោក នូត សាគុណ
៦- លោក ម៉េង សាម៉េត

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក ហូត ចណ្ណ:
២- លោក គីម សំអាត
៣- លោក ហេង សារ៉ែន
៤- លោក ហៀង ហួន
៥- លោក សួស សិទ្ធ
៦- លោក គីម សំអាត់
៧- កញ្ញា អ៊ឹម រ៉ាវី
៨- លោក ឡុង និមល

[illegible] ១២១២.១០២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៩៧៩ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ[illegible] ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
[illegible]ខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ទៀវ សុគន្ធ** ជាអនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣រល. ១២១២. ១០២៧*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២*

លេខៈ៩៨៣ ច.ល
[illegible]ចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១២
[illegible]ទីស្តីការរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងឯកឧត្តម **នេត បារ៉ុម** ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣៣៩.១២១២.១០២៩*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២*

លេខ [illegible] ច.ល

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

[illegible] ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** កាត់ផ្ទៃដីទំហំ ១៧១ ហិកតា ពីឧទ្យានជាតិកែប នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ១ លេខរៀងទី ៣ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ៩៨១ ច.ល
...ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល
... សុខា

៣៥៩.១២១២.១០៧៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧១៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃ ទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- បានឃើញប្រកាសលេខ១១០៧ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១**: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាមិនមែនកម្មវិធីជំពូក ៦៥ (ឧបត្ថម្ភធន និង ជំនួយសង្គម) ចំនួនៈ ៧៦០.០០០.០០០រៀល (ប្រាំពីររយហុកសិបលានរៀលគត់) មកថវិកាមិនមែនកម្មវិធី ជំពូក ៦០ (ការទិញ) ចំនួនៈ ២៥.០០០.០០០រៀល (ម្ភៃប្រាំលានរៀលគត់) ជំពូក ៦១ (សេវាខាងក្រៅ) ចំនួនៈ ៣៥.០០០.០០០រៀល (សាមសិបប្រាំលានរៀលគត់) និងជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួនៈ ៧០០.០០០.០០០រៀល (ប្រាំពីររយលានរៀលគត់) ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែង សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០១២។

**មាត្រា២**: ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ***ហ៊ុន សែន*** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧១៨ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី

**ការកាត់ដីសរុបទំហំ ១១.៤៩៤,៥៥ ហិកតា ដែលក្នុងនោះ (១). កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣, (២).ពីក្រុមហ៊ុន HLH, (៣).ពីក្រុមហ៊ុន Great Field (៤).ពីក្រុមហ៊ុន Future Environment, និង(៥).ពីក្រុមហ៊ុន Yee Jia ដើម្បីធ្វើអនុបយោគជាដីឯជនរបស់រដ្ឋនូវទំហំ ៦.១០១,៨២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.៦៩៩ គ្រួសារ និងទំហំ ៥.៣៩២,៧៣ ហិកតា រក្សាទុកសម្រាប់ជាដីសាធារណៈរបស់រដ្ឋ និងស្នើសុំផ្ដល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង ចំនួន ២.៦៩៩ គ្រួសារ លើ ៧.១០៧ ក្បាលដី នូវផ្ទៃដីទំហំ ៦.១០១,៨២ ហិកតា នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពី ការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១០១១ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៥៦៧ អបខ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ **១១.៤៩៤,៥៥ ហិកតា** ដែលក្នុងនោះ (១). ផ្ទៃដីទំហំ១០.៨១៩,៤៨ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុច ២ លេខរៀងទី ៨ (២). ផ្ទៃដីទំហំ ៥៦៥,៨៦ ហិកតា ពីក្រុមហ៊ុន HLH, (៣). ផ្ទៃដីទំហំ ៣៧,៥៩ ហិកតា ពីក្រុមហ៊ុន Great Feild (៤). ផ្ទៃដីទំហំ៦៦,៥៦ ហិកតា ពីក្រុមហ៊ុន Future Environment, និង(៥). ផ្ទៃដីទំហំ ៤,៩៦ ហិកតា ពីក្រុមហ៊ុន Yee Jia ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ៦.១០១,៨២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ **៥.៣៩២,៧៣ ហិកតា** រក្សាទុកសម្រាប់ជាដីសាធារណៈរបស់រដ្ឋ នៅឃុំត្រពាំងជោ និងឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលមានទំហំ និងចំនួនគ្រួសារ ស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម៖

ក.១ ឃុំគ្រពាំងដោមាន ០៦ភូមិ រួមមាន៖

- ផ្ទៃដីសរុបទំហំ ៥០៧.៩៨ ហិកតា ក្នុងនោះ (១) ផ្ទៃដីទំហំ ៤៦១,៦៤ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ និង(២) ផ្ទៃទំហំ ៤៦,៣៤ ហិកតា ពីក្រុមហ៊ុន HLH ដើម្បីអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣១១,០៦ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៩៦,៩២ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិលាក់តាន

- ផ្ទៃដីសរុបទំហំ ១.១៩១,៥៩ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤៥២,២៥ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៧៣៩,៣៤ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិក្បាលដំរី

- ផ្ទៃដីសរុបទំហំ ៧៩០,៤៦ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤៩៣,៥៣ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៩៦,៩៣ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិក្រវៀក

- ផ្ទៃដីសរុបទំហំ ១.២៩១,៧៧ ហិកតា ក្នុងនោះ (១). ផ្ទៃដីទំហំ ១.២៦១,០៦ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ និង(២) ផ្ទៃទំហំ ៣០,៧១ ហិកតា ពីក្រុមហ៊ុន Great Field ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៣៩៦,៣៩ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៨៩៥,៣៨ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិសំរោង

- ផ្ទៃដីសរុបទំហំ ១.២៣៥,២៨ ហិកតា ក្នុងនោះ (១) ផ្ទៃដីទំហំ ១.១៩៨,៣៦ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ និង(២) ផ្ទៃទំហំ ៣៦,៩២ ហិកតា ពីក្រុមហ៊ុន HLH ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤៤៥,២១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៧៩០,០៧ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិត្រោង

- ផ្ទៃដីសរុបទំហំ ១.៨៩៨,១២ ហិកតា ក្នុងនោះ (១) ផ្ទៃដីទំហំ ១.៤១៥,៤២ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ (២) ផ្ទៃដីទំហំ ៤៨២,៧០ ហិកតា ពីក្រុមហ៊ុន HLH ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៩៦៥,៧៨ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៩៣២,៣៤ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិចំបក់

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

ក.២. ឃុំតាសាលមាន ០៩ភូមិ រួមមាន៖

- ផ្ទៃដីសរុបទំហំ ៤២៧,០៥ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២១១,៦២ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២១៥,៤៣ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិដូនជន

- ផ្ទៃដីសរុបទំហំ ២១៧,៥៨ ហិកតា ក្នុងនោះ (១) ផ្ទៃដីទំហំ ១៥១,០២ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ និង(២) ផ្ទៃទំហំ ៦៦,៥៦ ហិកតា ពីក្រុមហ៊ុន Future Environment ដើម្បីធ្វើអនុបយោគ

ជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១២៥,៨១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៩១,៧៧ ហិកតារក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិស្វាយ

- ផ្ទៃដីសរុបទំហំ ៥២៩,៥៧ ហិកតា ក្នុងនោះ (១) ផ្ទៃដីទំហំ ៥២២,៦៩ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ និង (២) ផ្ទៃទំហំ ៦,៨៨ ហិកតា ពីក្រុមហ៊ុន Great Field ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២៩៥,៦៦ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៣៣,៩១ ហិកតារក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិថ្មី

- ផ្ទៃដីសរុបទំហំ ៥២៦,២៤ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤៣០,០៦ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៩៦,១៨ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិតាសាល

- ផ្ទៃដីសរុបទំហំ ៥៣១,៨៣ ហិកតា ក្នុងនោះ (១) ផ្ទៃដីទំហំ ៥២៦,៨៧ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ និង(២) ផ្ទៃទំហំ ៤,៩៦ ហិកតា ពីក្រុមហ៊ុន Yee Jia ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤៦៨,៧២ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និងទំហំ ៦៣,១១ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិកំប៉េះ

- ផ្ទៃដីសរុបទំហំ ២៥០,១០ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២១៣,៥៦ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣៦,៥៤ ហិកតារក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិពោងម៉ាស៊ីន

- ផ្ទៃដីសរុបទំហំ ៣៥១,២៤ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២៨៩,៥៥ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦១,៦៩ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិកោះរុន

- ផ្ទៃដីសរុបទំហំ ៦០៦,៤៨ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៣៣៩,៨១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៦៦,៦៧ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិក្នុងអាយ

- ផ្ទៃដីសរុបទំហំ ១.១៣៩,២៦ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៦៦២,៨១ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និងទំហំ ៤៧៦,៤៥ ហិកតា រក្សាទុកជាដីសាធារណៈរដ្ឋ នៅក្នុងភូមិត្រពាំងធ្លា

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៤ ឧបសម្ព័ន្ធទី៥ និងឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណាត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ

ចំនួន ២.៦៩៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅខេត្តកំពង់ស្ពឺ ស្រុកឱរ៉ាល់ ឃុំត្រពាំងជោ និងឃុំតាសាល ក្នុងភូមិដូចខាងក្រោម ៖

២.១ ឃុំត្រពាំងជោមាន ០៦ ភូមិ រួមមាន ៖

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១០៣ គ្រួសារ នៅភូមិលាក់តាន
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៨០ គ្រួសារ នៅភូមិក្បាលដំរី
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១០០ គ្រួសារ នៅភូមិក្រវៀក
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៣៦ គ្រួសារ នៅភូមិសំរោង
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៨៦ គ្រួសារ នៅភូមិគ្រាំង
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៨១ គ្រួសារ នៅភូមិចំបក់។

២.២. ឃុំតាសាល មាន ០៩ ភូមិ រួមមាន ៖

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១៦ គ្រួសារ នៅភូមិដូនជន់
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៦០ គ្រួសារ នៅភូមិសូរិយា
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៥២ គ្រួសារ នៅភូមិថ្មី
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២២២ គ្រួសារ នៅភូមិតាសាល
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៩២ គ្រួសារ នៅភូមិកំប៉េះ
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៨២ គ្រួសារ នៅភូមិរោងម៉ាស៊ីន
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៨៣ គ្រួសារ នៅភូមិកោះរុន
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៧១ គ្រួសារ នៅភូមិក្នុងអាយ
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៣៥ គ្រួសារ នៅភូមិត្រពាំងផ្នា។

**មាត្រា ៣ .-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៧.១០៧ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២.៦៩៩ គ្រួសារ លើក្បាលដី ៧.០៩០ ក្បាលដី ដីសមូហភាពរបស់វត្តចំនួន ០៣ ក្បាលដី ដីសាធារណៈរបស់រដ្ឋចំនួន ០៧ ក្បាលដី (សាលារៀនចំនួន ០៣ ក្បាលដី, ដីស្នាក់ការភូមិចំនួន ០៤ ក្បាលដី), និងដីកម្មសិទ្ធិអវិភាគ ០៧ ក្បាលដី (ដីទួលកប់ខ្មោច ០២ ក្បាលដី, ដីទួលអ្នកតា ០១ ក្បាលដី, ដីរួមភូមិ ០៣ ក្បាលដី, ដីស្រះរួមភូមិ ០១ក្បាលដី) ដែលក្នុងនោះ ៖

៣.១. នៅឃុំត្រពាំងជោ ស្រុកឱរ៉ាល់

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៣០៧ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១០៣ គ្រួសារ នៅភូមិលាក់តាន
- ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុបចំនួន ៥២៥ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋជាកម្មសិទ្ធិឯកជនចំនួន ១៨០ គ្រួសារ លើក្បាលដីចំនួន ៥២២ក្បាលដី និងកម្មសិទ្ធិសមូហភាពចំនួន

០១ ក្បាលដី(ដីវត្ត) ដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (សាលារៀន) និងកម្មសិទ្ធិអវិភាគរបស់សហគមន៍ភូមិ ០១ ក្បាលដី (ដីទួលកប់ខ្មោច) នៅភូមិក្បាលដំរី

- ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុបចំនួន ៦០០ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋជាកម្មសិទ្ធិឯកជនចំនួន ១០០ គ្រួសារ លើក្បាលដីចំនួន ៥៩៨ ក្បាលដី និងដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (សាលារៀន) និងដីកម្មសិទ្ធិអវិភាគរបស់សហគមន៍ភូមិ ០១ ក្បាលដី (ដីរូមភូមិ) នៅភូមិក្រវៀក
- ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុបចំនួន ៥១១ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋជាកម្មសិទ្ធិឯកជនចំនួន ១៣៦ គ្រួសារ លើក្បាលដីចំនួន ៥០៨ក្បាលដី ដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ស្នាក់ការភូមិ) និងដីកម្មសិទ្ធិអវិភាគរបស់សហគមន៍ភូមិ ០២ ក្បាលដី (ដីទួលអ្នកតា, ដីរូមភូមិ) នៅភូមិសំពោង
- ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុបចំនួន ៩៣៥ក្បាលដី ជូនប្រជាពលរដ្ឋជាកម្មសិទ្ធិឯកជនចំនួន ១៨៦គ្រួសារ នៅភូមិត្រាង
- ផ្តល់សិទ្ធិជាកម្មសិទ្ធិសរុបចំនួន ៦៩០ក្បាលដី ជូនប្រជាពលរដ្ឋជាកម្មសិទ្ធិឯកជនចំនួន ២៨១គ្រួសារ នៅភូមិចំបក់។

៣.២. នៅក្នុងឃុំតាសាល ស្រុកឱរ៉ាល់

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២៧៧ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១១៦ គ្រួសារ លើក្បាលដីចំនួន ២៧៦ ក្បាលដី និងកម្មសិទ្ធិសម្ហូភាព ០១ ក្បាលដី (ដីវត្ត) នៅភូមិដូនជន់
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីសរុបចំនួន ១៩៥ក្បាលដី ជូនប្រជាពលរដ្ឋ ចំនួន ៦០ គ្រួសារ នៅភូមិសូរិយា
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីសរុបចំនួន ៩៨៥ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៥២ គ្រួសារ នៅភូមិថ្មី
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីសរុបចំនួន ៥៩៦ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២២២ គ្រួសារ នៅភូមិតាសាល
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីសរុបចំនួន ៩៩៥ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៩២ គ្រួសារ នៅភូមិកំប៉េះ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៣៣៥ ក្បាលដី ក្នុងនោះ ក្បាលដីចំនួន ៣៣១ក្បាលដី ជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៨២ គ្រួសារ និងកម្មសិទ្ធិសម្ហូភាព ០១ ក្បាលដី(ដីវត្ត) កម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០២ ក្បាលដី (សាលារៀន និងស្នាក់ការភូមិ) និងកម្មសិទ្ធិអវិភាគ សហគមន៍ភូមិចំនួន ០១ ក្បាលដី (ដីទួលកប់ខ្មោច) នៅភូមិរោងម៉ាស៊ីន

- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៣៧៩ក្បាលដី ក្នុងនោះ ក្បាលដីចំនួន ៣៧៨ក្បាលដី ជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៨៣ គ្រួសារ និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ស្នាក់ការភូមិ) នៅភូមិកោះរុន
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៩៦៨ក្បាលដី ក្នុងនោះ ក្បាលដីចំនួន ៩៦៦ ក្បាលដី ជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៧១គ្រួសារ និងកម្មសិទ្ធិអវិភាគរបស់សហគមន៍ភូមិចំនួន ០២ ក្បាលដី (ដីរួមភូមិ និងដីស្រះរួមភូមិ) នៅភូមិក្នុងអាយ
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៩០៨ក្បាលដី ក្នុងនោះ ក្បាលដីចំនួន ៩០៧ក្បាលដី ជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៣៥ គ្រួសារ និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០១ក្បាលដី (ស្នាក់ការភូមិ) នៅភូមិត្រពាំងថ្នា។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្ដែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧១៧ អនក្រ.បក.

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២.២៩៧.០៨ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដែលក្នុងនោះទំហំ ២.១៨២,៨២ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.៣៣៤ គ្រួសារ និងដីទំហំ ១១៤,២៦ ហិកតា រក្សាទុកសម្រាប់ជាដីសាធារណៈរបស់រដ្ឋនិងស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ២.៣៣៤ គ្រួសារ លើ ៣.៣៩៩ ក្បាលដី ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅក្នុងស្រុក ឧដុង្គ ខេត្ត កំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៥៦៨ អបខ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ២.២៩៧,០៨ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ២.១៨២,៨២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ១១៤,២៦ ហិកតា រក្សាទុកសម្រាប់ជាដីសាធារណៈរបស់រដ្ឋ នៅឃុំជំពូព្រឹក្ស ឃុំត្រាចទង និងឃុំមានជ័យ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែលមានទំហំ និងចំនួនគ្រួសារ ស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

**១. ឃុំជំពូព្រឹក្ស ០៦ ភូមិ រួមមាន ៖**

១.១. ផ្ទៃដីសរុបទំហំ ១៥,៣៨ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១៤,០៨ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១,៣០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិត្រពាំងលៀប

១.២. ផ្ទៃដីសរុបទំហំ ១០៣,១៤ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៩៨,៧៧ ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤,៣៧ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិត្រាចខ្ពស់

១.៣. ផ្ទៃដីសរុបទំហំ ២៥២,៥៦ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ២៣៩,៧៥ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១២,៨១ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិព្រៃអំពិល

១.៤.ផ្ទៃដីសរុបទំហំ ៧២,២៣ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៦៧,៨៧ ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤,៣៧ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិច្រកពព្វល

១.៥.ផ្ទៃដីសរុបទំហំ ៥៦,៨៣ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤៩,៨៥ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦,៩៨ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិក្រាំងតាសោម

១.៦.ផ្ទៃដីសរុបទំហំ ១៩៩,៧២ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១៨៩,៣៣ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១០,៣៩ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិជំពូព្រឹក្ស។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

**២. ឃុំក្រាំងទង មាន ១៣ ភូមិ រួមមាន ៖**

២.១.ផ្ទៃដីសរុបទំហំ ២៣៣,២៣ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ២២០,១៩ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៣,០៤ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិត្រាំងក្ដុល

២.២. ផ្ទៃដីសរុបទំហំ ៨២,៦៤ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៧៩,៩៤ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២,៧០ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិបឹងវ៉ា

២.៣.ផ្ទៃដីសរុបទំហំ ១២០,៦៨ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១១៤,៥៩ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦,០៩ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិក្រាំងគ្រប់

២.៤.ផ្ទៃដីសរុបទំហំ ៦,៣៦ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៥,៩៦ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០,៤០ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិទួលខ្លុង

២.៥.ផ្ទៃដីសរុបទំហំ ៦៧,៤០ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៦៤,៥០ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២,៩០ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិក្រសាំងផ្អែម

២.៦.ផ្ទៃដីសរុបទំហំ ២៤,៦២ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២៤,៤២ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០,២០ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិត្រពាំងលើក

២.៧.ផ្ទៃដីសរុបទំហំ ២៤០,៨២ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ២៣៤,២៧ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦,៥៥ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិអណ្ដូងច្រុះ

២.៨.ផ្ទៃដីសរុបទំហំ ១០៤,៦១ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១០១,៧៤ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២,៨៧ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិឫស្សីមួយគុម្ព

២.៩.ផ្ទៃដីសរុបទំហំ ១៥៣,៩២ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១៤៥,៩៩ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៧,៩៣ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិបឹង

២.១០.ផ្ទៃដីសរុបទំហំ ១០៨,៣៤ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១០៤,៧៥ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣,៥៩ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិត្រពាំងអង្គ្រង

២.១១.ផ្ទៃដីសរុបទំហំ ១៣,៦២ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១៣,២៣ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០,៣៩ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិស្រះស្ដេច

២.១២.ផ្ទៃដីសរុបទំហំ ១៦៥,០៧ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១៥៨,៩០ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦,១៧ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិឃ្លាំង

២.១៣.ផ្ទៃដីសរុបទំហំ ១៩៩,៦៩ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ១៨៣,៨៥ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៥,៨៤ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិរាំ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៤ ឧបសម្ព័ន្ធទី៥ ឧបសម្ព័ន្ធទី៦ និងឧបសម្ព័ន្ធទី ៧ នៃអនុក្រឹត្យនេះ។

៣. ឃុំមានជ័យ មាន 02 ភូមិ រួមមាន ៖

៣.១.ផ្ទៃដីសរុបទំហំ ៥៣,២០ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤៩,៣៧ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣,៨៣ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិស្អុកស្អាត

៣.២.ផ្ទៃដីសរុបទំហំ ២៣,៩២ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ២២,៣៨ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១,៥៤ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិស្អុក។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យនេះ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៣៣៤ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅខេត្តកំពង់ស្ពឺ ស្រុកឱរ៉ាល់ ឃុំត្រពាំងជោ និងឃុំតាសាល ក្នុងភូមិដូចខាងក្រោម៖

២.១. ឃុំជំពូព្រឹក្ស ០៦ ភូមិ រួមមាន ៖

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩០គ្រួសារ នៅភូមិត្រពាំងលៀប
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៣៥ គ្រួសារ នៅភូមិត្រាចខ្ពស់
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២១៩ គ្រួសារ នៅភូមិព្រៃអំពិល
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៨១ គ្រួសារ នៅភូមិច្រកពពូល
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២០៤ គ្រួសារ នៅភូមិក្រាំងតាសោម
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៦១ គ្រួសារ នៅភូមិជំពូព្រឹក្ស។

២.២. ឃុំត្រាចទង មាន ១៣ ភូមិ រួមមាន ៖

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៩៨ គ្រួសារ នៅភូមិត្រពាំងក្តុល
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៧៣ គ្រួសារ នៅភូមិបឹងវ៉ា
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១៧ គ្រួសារ នៅភូមិក្រាំងគ្រប់
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ០៣ គ្រួសារ នៅភូមិទួលខ្លុង
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៧០ គ្រួសារ នៅភូមិក្រសាំងផ្អែម
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២០ គ្រួសារ នៅភូមិត្រពាំងលើក
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧៧ គ្រួសារ នៅភូមិអណ្តូងច្រុះ
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩២ គ្រួសារ នៅភូមិឫស្សីមួយគុម្ព
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១៧ គ្រួសារ នៅភូមិបឹង

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៨២ គ្រួសារ នៅភូមិត្រពាំងអង្គ្រង
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ០៥ គ្រួសារ នៅភូមិស្រះស្តេច
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៦២ គ្រួសារ នៅភូមិឃ្លាំង
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២០១ គ្រួសារ នៅភូមិពា។

២.៣.ឃុំមានជ័យ មាន ០២ភូមិរួមមាន ៖

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១០៨ គ្រួសារ នៅភូមិស្តុកស្អាត
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៩ គ្រួសារ នៅភូមិស្តុក។

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៣៩៩ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៣៣៨ គ្រួសារ លើក្បាលដី ៣៣៨០ ក្បាលដី កម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០៩ ក្បាលដី (សាលារៀន ០៣ ក្បាលដី, ដីស្នាក់ការភូមិ ០២ ក្បាលដី សាលាឃុំ ០១ក្បាលដី ប៉ុស្តិ៍រដ្ឋបាលឃុំ ០១ក្បាលដី ត្រពាំងទឹក ០១ក្បាលដី និងទួលអង្គ ០១ក្បាលដី), កម្មសិទ្ធិអវិភាគសហគមន៍ភូមិ ០៩ ក្បាលដី (ស្រះទឹក ០៨ក្បាលដី និងទួលកប់ខ្មោច ០១ ក្បាលដី) និងកម្មសិទ្ធិសម្ពហភាព ០១ក្បាលដី (ដីវត្ត ០១ក្បាលដី) ដែលក្នុងនោះ ៖

៣.១. នៅឃុំជំពូព្រឹក្ស ស្រុកឧដុង្គ៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៩២ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ៩០ គ្រួសារនៅភូមិត្រពាំងលៀប
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ២០២ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ១៣៥ គ្រួសារនៅភូមិក្រាចខ្ពស់
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៥៦៤ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ២១៩ គ្រួសារនៅភូមិព្រៃអំពិល
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១០៨ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ៨១ គ្រួសារនៅភូមិច្រកពពូល
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២៥៦ក្បាលដីក្នុងនោះផ្តល់សិទ្ធជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២០៨គ្រួសារលើក្បាលដីចំនួន ២៥៤ក្បាលដីនិងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០២ក្បាលដី*(ដីសាលាឃុំ និងប៉ុស្តិ៍រដ្ឋបាល)*នៅភូមិក្រាំងតាសោម
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២៣៨ក្បាលដីក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៦១គ្រួសារលើក្បាលដីចំនួន ២៣៦ក្បាលដីនិងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០១ក្បាលដី*(សាលារៀន)*និងកម្មសិទ្ធិសម្ពហភាព ០១ក្បាលដី(វត្ត) នៅភូមិជំពូព្រឹក្ស។

៣.២. នៅក្នុងឃុំក្រាំចទង ស្រុកឧដុង្គ ៖

- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៣៧៥ក្បាលដីក្នុងនោះផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៩៨ គ្រួសារលើក្បាលដីចំនួន ៣៧៣ក្បាលដី និងកម្មសិទ្ធិសាធារណៈ ០២ ក្បាលដី*(សាលារៀន និងត្រពាំង)*នៅភូមិត្រពាំងក្ដុល
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ១១៣ក្បាលដីក្នុងនោះផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៧៣ គ្រួសារលើក្បាលដីចំនួន ១១១ក្បាលដីនិងកម្មសិទ្ធិអវិភាគសហគមន៍ភូមិ ០២ ក្បាលដី*(ទួលកប់ខ្មោច និងស្រះទឹក)*នៅភូមិបឹងរាំ
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២២៣ក្បាលដីក្នុងនោះផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១១៧ គ្រួសារលើក្បាលដីចំនួន ២២២ក្បាលដីនិងកម្មសិទ្ធិអវិភាគសហគមន៍ភូមិ ០១ក្បាលដី *(ស្រះទឹក)*នៅភូមិក្រាំងគ្រប់
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ០៣ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ០៣ គ្រួសារនៅភូមិទួលខ្លុង
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៨៤ក្បាលដី ក្នុងនោះផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៧០ គ្រួសារលើក្បាលដីចំនួន ៨៣ក្បាលដីនិងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០១ ក្បាលដី*(ទួលអង្គ)*នៅភូមិក្រសាំងផ្អែម
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ២២ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ២០គ្រួសារនៅភូមិត្រពាំងលើក
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២៥៤ក្បាលដីក្នុងនោះផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៧៧គ្រួសារលើក្បាលដីចំនួន ២៥១ក្បាលដី និងកម្មសិទ្ធិអវិភាគសហគមន៍ភូមិ ០២ ក្បាលដី*(ស្រះទឹក)*និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០១ ក្បាលដី(សាលារៀន) នៅភូមិអណ្ដូងច្រុះ
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៤៦ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ៤២ គ្រួសារនៅភូមិឫស្សីមួយគុម្ព
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៥១ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ១១៧គ្រួសារនៅភូមិបឹង
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ៩៨ក្បាលដីក្នុងនោះផ្ដល់សិទ្ធជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៨២ គ្រួសារលើក្បាលដីចំនួន ៩៧ក្បាលដី និងកម្មសិទ្ធិអវិភាគសហគមន៍ភូមិ ០១ ក្បាលដី*(ស្រះទឹក)*នៅភូមិត្រពាំងអង្គ្រង
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ០៥ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ០៥គ្រួសារនៅស្រះស្ដេច
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ២៥០ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ១៦២គ្រួសារនៅភូមិឃ្លាំង
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២៥៧ក្បាលដីក្នុងនោះផ្ដល់សិទ្ធជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២០១ គ្រួសារលើក្បាលដីចំនួន ២៥៤ក្បាលដី និងកម្មសិទ្ធិ

អភិភាគសហគមន៍ភូមិ ០២ ក្បាលដី *(ស្រះទឹក)* និងកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០១ក្បាលដី (ស្នាក់ការភូមិ) នៅភូមិវ៉ា

៣.៣. នៅក្នុងឃុំមានជ័យ ស្រុកឧដុង្គ៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុបចំនួន ២០១ក្បាលដីក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១០៨ គ្រួសារលើក្បាលដីចំនួន ១៩៩ក្បាលដី និងកម្មសិទ្ធិសាធារណៈ ០១ ក្បាលដី *(ស្នាក់ការភូមិ)* និងកម្មសិទ្ធិអភិភាគសហគមន៍ភូមិ ០១ ក្បាលដី (ស្រះទឹក) នៅភូមិស្តុកស្លាត
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៩ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ១៩គ្រួសារនៅភូមិស្តុក។

**មាត្រា ៤.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧២០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

**ការធ្វើអនុបយោគកាត់ដី (១) ទំហំ ៦០៣,៩៧ ហិកតា ចេញពីតម្រូវព្រៃឈើ ២០០២ និង(២) ទំហំ ១៣២.០៨ ហិកតា ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អាន ម៉ាឌី ដើម្បីធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ និងគោរពស្នើសុំប្រទានកម្មដីទំហំ ៣៧១,៤៩ ហិកតា ជំនួស សម្បទានសង្គមកិច្ច សម្រាប់ប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប ៦១៥ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ចំនួន ១.០៧៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ៦១៥ គ្រួសារ លើ ១.០៧៥ ក្បាលដី និងកម្មសិទ្ធិអវិភាគ ០១ ក្បាលដី (ទួលអប់ខ្មោច) នៅឃុំគគីរ និងឃុំគ្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៩ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ_សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ១១១២ ឧស៥-កទ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២២៧១ /១២ គ.វ.ក ចុះថ្ងៃទី០២.១០.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អេ ជេ ខាតធើរ (ខេមបូឌា) លីមីធីត ចុះថ្ងៃទី២០.០៩.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អេ & ជេ ខាតធើរ (ខេមបូឌា) លីមីធីត ( A & J CARTER (CAMBODIA) LIMITED. តំណាងដោយ លោក JONATHAN MARK CRUTCHLEY សញ្ជាតិអង់គ្លេស អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 508122391 ចុះថ្ងៃទី០៤.០៩.២០១២ មានអាសយដ្ឋានបច្ចុប្បន្ន៖ Room 1602-1603,16/F., Park Building,476 Castle Peak Road,Cheung Sha Wan ,Kowloon,Hong Kong. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

- **ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រកាត់ដេរសម្លៀកបំពាក់ អេ & ជេ ខាតជើរ (ខេមបូឌា) លីមីធីត "*
- **ទីតាំងរោងចក្រ ៖** *"ផ្លូវជាតិលេខ៤ ភូមិវិថ្លល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ-សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤,, "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៥៦ ប្រក.កសក

# ប្រកាស
# ស្តីពី
# នីតិវិធីនិងការគម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្មគ្រប់ប្រភេទ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅធានានូវគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពនៃថ្នាំកសិកម្មគ្រប់ប្រភេទ ដោយអនុលោមតាមការតម្រូវបមាណីយ នៅមុនពេលអនុញ្ញាតឲ្យធ្វើការនាំចូលនាំចេញ ធ្វើការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីសម្រាប់ការផ្គត់ផ្គង់ចែកចាយឬធ្វើចរាចរណ៍លើទីផ្សារ និងការប្រើប្រាស់គ្រប់រូបភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះថ្នាំកសិកម្មគ្រប់ប្រភេទ និងសារធាតុសកម្ម ឬសមាសធាតុផ្សេងទៀតនៃថ្នាំកសិកម្មដែលត្រូវបានប្រើប្រាស់សម្រាប់ការការពារការបំផ្លាញ ការកម្ចាត់ការទាក់ទាញ ការបណ្តេញដោយផ្ទាល់ឬដោយប្រយោល នូវសមាសភាពចង្រៃណាមួយ។

ដោយផ្អែកតាមសមាសធាតុនិងមុខសញ្ញាប្រើប្រាស់ ថ្នាំកសិកម្មមានចំណាត់ថ្នាក់ដូចខាងក្រោម៖

ក- ថ្នាំកសិកម្មគីមី

១-ថ្នាំកសិកម្មប្រើប្រាស់ក្នុងផលិតកម្មកសិកម្មនិងសួនគេហដ្ឋាន។

២-ថ្នាំកសិកម្មប្រើប្រាស់ក្នុងលំនៅឋាន និងសម្រាប់សុខភាពសាធារណៈ។

៣-ថ្នាំកសិកម្មគីមីផ្សេងទៀត។

ខ- ថ្នាំកសិកម្មជីវសាស្ត្រ

១- ភ្នាក់ងារកម្ចាត់សមាសភាពចង្រៃជីវគីមី។

២- ភ្នាក់ងារកម្ចាត់សមាសភាពចង្រៃមីក្រូជីវសាស្ត្រ។

ប្រភេទថ្នាំកសិកម្មតាមចំណាត់ថ្នាក់នីមួយៗត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

# ជំពូកទី ២
# ការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម

**ប្រការ ៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម មានកាតព្វកិច្ចបំពេញការតម្រូវបមាណីយ ដោយត្រូវផ្តល់ទិន្នន័យនិងព័ត៌មានពេញលេញ ពិតត្រឹមត្រូវ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់លើសេចក្តីបញ្ជាក់អះអាងរបស់ខ្លួន។

ដើម្បីស្នើសុំការចុះបញ្ជីថ្នាំកសិកម្មក្នុងគោលបំណងធ្វើពាណិជ្ជកម្មបាន លុះត្រាតែនីតិបុគ្គលនោះបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សំណើសុំការចុះបញ្ជីថ្នាំកសិកម្មសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម ពុំតម្រូវឲ្យភ្ជាប់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឡើយ។

ការិយាល័យតំណាងពាណិជ្ជកម្មឬទីភ្នាក់ងារពាណិជ្ជកម្ម សមាគម ឬអង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចស្នើសុំការចុះបញ្ជីថ្នាំកសិកម្មបានសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ប៉ុន្តែមិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មបានឡើយ។

**ប្រការ ៥.-**

ប្រភេទថ្នាំកសិកម្មដែលអាចស្នើសុំការចុះបញ្ជី រួមមានផលិតផលថ្នាំកសិកម្មឬសារធាតុសកម្មដែល៖

១- មិនស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។

២- ធ្លាប់បានទទួលការចុះបញ្ជី ប៉ុន្តែត្រូវបានផ្លាស់ប្តូរសមាសធាតុឬសារធាតុសកម្ម។

៣- ធ្លាប់បានទទួលការចុះបញ្ជី ប៉ុន្តែមានការកែប្រែលក្ខខណ្ឌ ទិន្នន័យ ឬព័ត៌មានបច្ចេកទេស។

៤- ធ្លាប់បានទទួលការចុះបញ្ជី ប៉ុន្តែមានប្រភពលាយផ្សំថ្មី។

៥- ជាល្បាយចម្រុះរវាងជីកសិកម្មនិងថ្នាំកសិកម្ម។

៦- ជាល្បាយចម្រុះរវាងប្រភេទថ្នាំកសិកម្មផ្សេងគ្នា ដូចជាថ្នាំសម្លាប់សត្វល្អិតជាមួយថ្នាំការពារផ្សិត ឬជាមួយថ្នាំសម្លាប់ស្មៅ។

ចំពោះសំណើសុំការចុះបញ្ជីប្រភេទថ្នាំកសិកម្មស្ថិតក្រោមលក្ខខណ្ឌនៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតបានសម្រាប់តែការប្រើប្រាស់ជាក់លាក់ក្រៅគោលបំណងពាណិជ្ជកម្ម ឬការធ្វើសេវាកម្មកម្ចាត់សមាសភាពចង្រៃ ដែលមានលិខិតអនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប៉ុណ្ណោះ។

បញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើពាណិជ្ជកម្មថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំការចុះបញ្ជីថ្នាំកសិកម្មដោយឡែកពីគ្នាតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ក្នុងករណីនាំចូលផលិតផលថ្នាំកសិកម្មសម្រាប់ផ្គត់ផ្គង់ចែកចាយ ត្រូវធ្វើការចុះបញ្ជីផលិតផលថ្នាំកសិកម្មនោះ។

២- ក្នុងករណីនាំចូលសារធាតុសកម្មឬរូបធាតុបច្ចេកទេសនៃថ្នាំកសិកម្មសម្រាប់ផ្គត់ផ្គង់ចែកចាយដល់គ្រឹះស្ថានផលិតលាយផ្សំឬវេចខ្ចប់ជាថ្មីនៅក្នុងស្រុក ត្រូវធ្វើការចុះបញ្ជីសារធាតុសកម្ម ឬរូបធាតុបច្ចេកទេសនៃថ្នាំកសិកម្មនោះ។

៣- ក្នុងករណីគ្រឹះស្ថានផលិតលាយផ្សំឬវេចខ្ចប់ជាថ្មីថ្នាំកសិកម្មនៅក្នុងស្រុក ដែលនាំចូលដោយផ្ទាល់នូវសារធាតុសកម្មឬរូបធាតុបច្ចេកទេសនៃថ្នាំកសិកម្មដើម្បីធ្វើការលាយផ្សំផលិតផលថ្នាំកសិកម្មថ្មី ត្រូវធ្វើការចុះបញ្ជីសារធាតុសកម្មឬរូបធាតុបច្ចេកទេសនៃថ្នាំកសិកម្មនោះ ព្រមទាំងធ្វើការចុះបញ្ជីផលិតផលថ្នាំកសិកម្មដែលបានផលិតលាយផ្សំនោះផង។

៤- ចំពោះផលិតផលថ្នាំកសិកម្មទាំងឡាយណាដែលមានសារធាតុសកម្មចំនួន០២(ពីរ) ឬលើស សំណើសុំការធ្វើវិភាគត្រូវអនុវត្តចំពោះសារធាតុសកម្មនីមួយៗ។

៥- អាចស្នើសុំការចុះបញ្ជីនិងទទួលការយល់ព្រមនៅពេលតែមួយ ចំពោះប្រភពតែមួយគត់នៃសារធាតុសកម្មថ្នាំកសិកម្ម។

**ប្រការ ៧.-**

ការតម្រូវឲ្យទៅនូវព័ត៌មាននិងទិន្នន័យសម្រាប់ការចុះបញ្ជីថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវបានកំណត់តាមកម្រងព័ត៌មានដូចខាងក្រោម៖

ក- ទិន្នន័យរូប-គីមី

១- សារធាតុសកម្មនៃថ្នាំកសិកម្ម

២- ផលិតផលថ្នាំកសិកម្មលាយផ្សំ។

ខ- ទិន្នន័យស្តីពីភាពពុលនៃថ្នាំកសិកម្ម។

គ- ទិន្នន័យជីវប្រសិទ្ធភាពចេញពីប្រទេសប្រភពដើមផលិតលាយផ្សំ ឬនៅប្រទេសណាមួយ (បើសិនជាមាន)។

ឃ- ទិន្នន័យស្តីពីសំណល់ថ្នាំកសិកម្ម។

ង- ទិន្នន័យស្តីពីភាពប្រឈមចំពោះសុខភាពមនុស្ស និងបរិស្ថាន។

ច- ទិន្នន័យស្តីពីស្លាកសញ្ញាព័ត៌មាន ការវេចខ្ចប់ និងការធ្វើសន្និធិ រួមជាមួយគំរូសំបកវេចខ្ចប់ និងគំរូស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៃប្រភេទថ្នាំកសិកម្មនីមួយៗ។

ឆ- ឯកសារផ្សេងទៀតត្រូវភ្ជាប់៖

ឆ.១- វិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគសារធាតុសកម្មចេញដោយប្រទេសប្រភពដើមផលិតឬនាំចេញ។

ឆ.២- លទ្ធផលវិភាគសារធាតុសកម្មចេញដោយមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ឆ.៣- លទ្ធផលពិសោធសាកល្បងជីវប្រសិទ្ធភាពចេញដោយស្ថានីយពិសោធន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ឆ.៤- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្មចេញពីប្រទេសប្រភពដើមផលិតលាយផ្សំឬនាំចេញ ឬចេញពីប្រទេសផ្សេងទៀត (បើសិនជាមាន)។

ឆ.៥- ព្រឹត្តិបត្រព័ត៌មានសុវត្ថិភាពចេញពីប្រទេសប្រភពដើមផលិតលាយផ្សំឬនាំចេញ។

ឆ.៦- គំរូសំបកវេចខ្ចប់ និងគំរូស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ។

ឆ.៧- សំណាកនៃថ្នាំកសិកម្ម។

សេចក្តីអះអាងព័ត៌មាននិងទិន្នន័យស្តីពីថ្នាំកសិកម្មដែលត្រូវស្នើសុំការចុះបញ្ជី ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

ការតម្រូវព័ត៌មាននិងទិន្នន័យសម្រាប់ការចុះបញ្ជីថ្នាំកសិកម្មជីវសាស្ត្រ នឹងត្រូវកំណត់ដោយឧបសម្ព័ន្ធបន្ថែមនៃប្រកាសនេះ។

**ប្រការ ៨.-**

ក្នុងករណីមានការកែប្រែលក្ខខណ្ឌ ទិន្នន័យ ឬព័ត៌មានណាមួយនៃថ្នាំកសិកម្ម រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាប្រភេទថ្នាំកសិកម្មនោះ ត្រូវស្នើសុំការចុះបញ្ជីជាថ្មី និងត្រូវភ្ជាប់ព្រឹត្តិបត្រព័ត៌មានសុវត្ថិភាពជាចាំបាច់ ដូចខាងក្រោម៖

១- ការពង្រីកការប្រើប្រាស់។

២- ការប្រែប្រួលរបៀបប្រើប្រាស់ កម្រិតប្រើប្រាស់ ពេលវេលាប្រើប្រាស់ និងចំនួនលើកប្រើប្រាស់។

៣- ការប្រែប្រួលដើម្បីបង្កើតកម្រិតសំណល់អតិបរមា។

៤- ការប្រែប្រួលរយៈពេលបញ្ឈប់ការប្រើប្រាស់មុនពេលប្រមូលផល។

៥- ការកែប្រែរូបមន្តផ្សំនៃថ្នាំកសិកម្ម រួមមាន៖

- ការកែប្រែសារធាតុសកម្មដែលត្រូវការទិន្នន័យជីវប្រសិទ្ធភាពជាចាំបាច់
- ការកែប្រែនូវសារធាតុនិចលដូចជាសារធាតុរំលាយនិងសារធាតុស្អិត ដែលត្រូវការព្រឹត្តិបត្រព័ត៌មានសុវត្ថិភាព និងទិន្នន័យជីវប្រសិទ្ធភាពជាចាំបាច់។

៦- ការផ្លាស់ប្តូរប្រភពលាយផ្សំឬសារធាតុសកម្មថ្មី៖

- ការប្រែប្រួលដំណើរការលាយផ្សំ ដែលនាំមកនូវការប្រែប្រួលកំហាប់នៃសារធាតុសកម្ម
- ការប្រែប្រួលប្រភពនៃសារធាតុសកម្មថ្មី ថ្នាំកសិកម្មប្រភពថ្មីនោះត្រូវស្នើសុំការចុះបញ្ជីជាថ្មី។

**ប្រការ ៩.-**

ឈ្មោះថ្នាំកសិកម្មដែលអាចអនុញ្ញាតឲ្យចុះបញ្ជីត្រូវមានលក្ខណៈដូចខាងក្រោម៖

- មិនត្រូវឲ្យមានភាពច្រឡំដល់សាធារណជន
- មិនត្រូវដូចគ្នាចំពោះផលិតផលពុលផ្សេងទៀត
- មិនត្រូវដូចគ្នាចំពោះប្រភេទចំណីអាហារផ្សេងៗ
- មិនត្រូវស្រដៀងគ្នានឹងឈ្មោះផលិតផលអ្វីមួយ។

**ប្រការ ១០.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ត្រូវដាក់ជូននាយកដ្ឋាននីតិកម្មកសិកម្មជាមួយពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម នូវសំណាកថ្នាំកសិកម្ម ដើម្បីបញ្ជូនធ្វើវិភាគដោយមន្ទីរពិសោធន៍ជាតិកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សំណើសុំការចុះបញ្ជីថ្នាំកសិកម្មត្រូវភ្ជាប់ទិន្នន័យអត្រាភាពសុទ្ធ វិធីសាស្ត្រកំណត់ភាពសុទ្ធ ទិន្នន័យស្តីពីគុណភាពវិភាគនិងគុណភាពបច្ចេកទេសនៃសំណាក ព្រឹត្តិបត្រព័ត៌មានសុវត្ថិភាព និងវិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគនៃសំណាកថ្នាំកសិកម្មចេញពីប្រភពដើមផលិតលាយផ្សំឬនាំចេញ។

សំណាកនីមួយៗនៃថ្នាំកសិកម្មសម្រាប់ធ្វើវិភាគមានដូចខាងក្រោម៖

១- សម្រាប់ផលិតផលថ្នាំកសិកម្ម មានចំនួន៣សំណាក៖

ក- សំណាករឹង៖ មានទម្ងន់យ៉ាងតិចពី៥០ទៅ១០០ក្រាម ចំនួន ២សំណាក។

ខ- សំណាករាវ៖ មានចំណុះយ៉ាងតិចពី៧៥ទៅ១០០មីល្លីលីត្រ ចំនួន ២សំណាក។

គ- សំណាកបមាណីយវិភាគនៃសារធាតុសកម្មថ្នាំកសិកម្មចំនួន១សំណាក ដែលមានបរិមាណ០.២៥ក្រាម ជាសំណាកកសិណសម្រាប់ផ្ទៀងផ្ទាត់ភាពសុទ្ធនៃសារធាតុសកម្មរបស់ថ្នាំកសិកម្ម។

២- សម្រាប់រូបធាតុបច្ចេកទេសឬសារធាតុសកម្មនៃថ្នាំកសិកម្ម មានទម្ងន់យ៉ាងតិចពី៥ទៅ១០ក្រាម ឬចំណុះយ៉ាងតិចពី៥ទៅ១០មីល្លីលីត្រចំនួន២សំណាក ព្រមទាំងសំណាកបមាណីយវិភាគ

នៃសារធាតុសកម្មថ្នាំកសិកម្មចំនួន១សំណាក ដែលមានបរិមាណ០.២៥ក្រាម ជាសំណាកកសិណ សម្រាប់ផ្ទៀងផ្ទាត់ភាពសុទ្ធនៃសារធាតុសកម្មរបស់ថ្នាំកសិកម្ម។

**ប្រការ ១១.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម អាចទទួលព័ត៌មានស្តីពីលទ្ធផលវិភាគសំណាកថ្នាំកសិកម្មនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលឯកសារស្នើសុំនិងសំណាកថ្នាំកសិកម្មសម្រាប់ធ្វើវិភាគ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើវិភាគសំណាកថ្នាំកសិកម្ម ត្រូវទទួលបន្ទុកលើការបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី ៣
## ទិន្នន័យជីវប្រសិទ្ធភាព

**ប្រការ ១២.-**

ទិន្នន័យស្តីពីជីវប្រសិទ្ធភាពនិងទិន្នន័យផ្សេងទៀតនៃថ្នាំកសិកម្ម គឺជាការតម្រូវបមាណីយចាំបាច់ដែលធានាថាផលិតផលថ្នាំកសិកម្មទទួលបាននូវប្រសិទ្ធភាពប្រឆាំងចំពោះសមាសភាពចង្រៃ និងធានាសុវត្ថិភាពចំពោះមនុស្ស សត្វ និងបរិស្ថាន ឆ្លើយតបតាមព័ត៌មានដែលចែងនៅក្នុងស្លាកសញ្ញាព័ត៌មានចេញពីប្រភពដើមផលិតឬប្រភពដើមលាយផ្សំ និងដែលបានអះអាងដោយអ្នកស្នើសុំការចុះបញ្ជី។

ទិន្នន័យជីវប្រសិទ្ធភាពអាចបង្កើតតាមរយៈការស្នើសុំពិសោធសាកល្បងលើទីវាលពិសោធន៍ដោយអនុលោមតាមពិធីសារបច្ចេកទេសសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម។ ការពិសោធសាកល្បងដើម្បីបង្កើតទិន្នន័យជីវប្រសិទ្ធភាពរបស់ថ្នាំកសិកម្ម ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- រដូវសាកល្បង
- ចំនួនលើកក្នុងការសាកល្បង
- ប្រភេទឬក្រុមប្រភេទដំណាំត្រូវសាកល្បង
- ប្រភេទឬក្រុមសមាសភាពចង្រៃ
- ទីតាំងឬតំបន់សាកល្បង។

**ប្រការ ១៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចទទួលស្គាល់ទិន្នន័យជីវប្រសិទ្ធភាពថ្នាំកសិកម្ម ដែលបង្កើតឡើងនៅក្នុងតំបន់ មានលក្ខខណ្ឌដូចគ្នានិងអនុលោមតាមពិធីសារសាកល្បងរបស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO) ឬពិធីសារបច្ចេកទេសសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ១៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម អាចស្នើសុំធ្វើវិភាគ និងធ្វើការពិសោធសាកល្បងជីវប្រសិទ្ធភាពជាមុន ដោយត្រូវដាក់ពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្មនោះនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើវិភាគឬធ្វើការពិសោធសាកល្បងជីវប្រសិទ្ធភាពសំណាកថ្នាំកសិកម្មសម្រាប់ការចុះបញ្ជី ត្រូវស្នើសុំលិខិតអនុញ្ញាតនាំចូលសំណាកថ្នាំកសិកម្មនោះជាមុន នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សំណាកថ្នាំកសិកម្មត្រូវបានអនុញ្ញាតឲ្យនាំចូលតាមបរិមាណសមស្របសម្រាប់តែបម្រើការធ្វើវិភាគ ការពិសោធសាកល្បងជីវប្រសិទ្ធភាព និងការសិក្សាទិន្នន័យថ្នាំកសិកម្មដែលពាក់ព័ន្ធសម្រាប់ការចុះបញ្ជី ដោយអនុលោមតាមពិធីសារបច្ចេកទេសសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្មប៉ុណ្ណោះ។

**ប្រការ ១៥.-**

ការពិសោធសាកល្បងជីវប្រសិទ្ធភាពនិងការសិក្សាទិន្នន័យថ្នាំកសិកម្មដែលពាក់ព័ន្ធ ត្រូវអនុវត្តដោយស្ថានីយពិសោធន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវកសិកម្មដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអនុលោមតាមពិធីសារបច្ចេកទេសសម្រាប់សាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម អាចទទួលព័ត៌មានស្តីពីលទ្ធផលសាកល្បងនៃថ្នាំកសិកម្មនោះ នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេលដូចខាងក្រោម៖

- ៦(ប្រាំមួយ)ទៅ១២(ដប់ពីរ)ខែឬលើស គិតចាប់ពីថ្ងៃទទួលឯកសារស្នើសុំនិងសំណាកថ្នាំកសិកម្មសម្រាប់ការពិសោធសាកល្បងជីវប្រសិទ្ធភាព
- ១២(ដប់ពីរ)ទៅ២៤(ម្ភៃបួន)ខែឬលើស គិតចាប់ពីថ្ងៃទទួលឯកសារស្នើសុំនិងសំណាកថ្នាំកសិកម្មសម្រាប់ការវាយតម្លៃលើទិន្នន័យផ្សេងទៀតនៃថ្នាំកសិកម្ម។

**ប្រការ ១៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម ត្រូវទទួលបន្ទុកលើការបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី ៤
## នីតិវិធីនិងដំណើរការសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម

**ប្រការ ១៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ត្រូវបំពេញពាក្យស្នើសុំនិងសំណុំបែបបទនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សំណុំឯកសារ ទិន្នន័យ ព័ត៌មានសម្រាប់ភ្ជាប់ជាមួយពាក្យស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ត្រូវរៀបចំលើក្រដាសទំហំA4(២១០x២៩៧មម) និងត្រូវចងក្រងក្នុងសឺមីក្រាស់ជាច់ដោយឡែកតាមយថាប្រភេទផលិតផលស្នើសុំចុះបញ្ជីនីមួយៗ ដែលនៅលើក្របក្រៅនៃសំណុំឯកសារត្រូវមានបង្ហាញនូវអត្តសញ្ញាណរបស់អ្នកស្នើសុំការចុះបញ្ជី។ នៅផ្នែកខាងលើបំផុតនៃកម្រងឯកសារ ត្រូវរៀបចំដាក់សំណុំឯកសារពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម រួមជាមួយឯកសារចុះបញ្ជីពាណិជ្ជកម្ម និងឯកសារផ្សេងទៀតដែលពាក់ព័ន្ធអត្តសញ្ញាណរបស់អ្នកស្នើសុំ។

បន្ទាប់មក ត្រូវរៀបចំកម្រងឯកសារតាមប្រភេទផលិតផលនីមួយៗដែលត្រូវចុះបញ្ជី ដែលមានមាតិកាតាមលំដាប់លំដោយដូចខាងក្រោម៖

១- សេចក្តីអះអាងព័ត៌មាននិងទិន្នន័យស្តីពីយថាប្រភេទថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី ដែលមានចំនួនមួយយថាប្រភេទថ្នាំកសិកម្មក្នុងមួយកម្រងព័ត៌មាន។

២- វិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគសារធាតុសកម្មចេញដោយប្រទេសប្រភពដើមផលិតលាយផ្សំឬនាំចេញ។

៣- លទ្ធផលវិភាគសារធាតុសកម្មចេញដោយមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤- លទ្ធផលពិសោធសាកល្បងជីវប្រសិទ្ធភាពចេញដោយស្ថានីយពិសោធន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្មចេញពីប្រទេសប្រភពដើមផលិតលាយផ្សំឬនាំចេញ ឬចេញពីប្រទេសផ្សេងទៀត (បើសិនជាមាន)។

៦- ព្រឹត្តិបត្រព័ត៌មានសុវត្ថិភាព ចេញដោយប្រទេសប្រភពដើមផលិតលាយផ្សំ។

៧- ទិន្នន័យរូប-គីមីនៃសារធាតុសកម្មឬផលិតផលថ្នាំកសិកម្មលាយផ្សំ។

៨- ទិន្នន័យស្តីពីភាពពុលនៃថ្នាំកសិកម្ម។

៩- ទិន្នន័យជីវប្រសិទ្ធភាពចេញពីប្រទេសប្រភពដើមផលិតលាយផ្សំ ឬនៅប្រទេសណាមួយ (បើសិនជាមាន)។

១០- ទិន្នន័យស្តីពីសំណល់ថ្នាំកសិកម្ម។

១១- ទិន្នន័យស្តីពីភាពប្រឈមចំពោះសុខភាពមនុស្ស និងបរិស្ថាន។

១២- ទិន្នន័យស្តីពីស្លាកសញ្ញាព័ត៌មាន ការវេចខ្ចប់ និងការធ្វើសន្និធិ រួមជាមួយគំរូសំបកវេចខ្ចប់ និងគំរូស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៃប្រភេទថ្នាំកសិកម្មនីមួយៗ។

១៣- សេចក្តីសង្ខេបទូទៅអំពីដំណើរការផលិតលាយផ្សំចេញពីប្រទេសប្រភពដើម។

១៤- របាយការណ៍ពិនិត្យ វាយតម្លៃទីតាំង និងដំណើរការលាយផ្សំសម្រាប់ផលិតកម្មក្នុងស្រុក។

១៥- CD Soft-copy នៃបញ្ជីឈ្មោះថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី គំរូស្លាកសញ្ញាព័ត៌មាន បរិយាយបណ្ណ័ និងឯកសារបច្ចេកទេសផ្សេងទៀតតាមការចាំបាច់។

ពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្មត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៣នៃប្រកាសនេះ។

**ប្រការ ១៨.-**

សំណុំឯកសារស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ត្រូវបានពិនិត្យដោយនាយកដ្ឋាននីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាមការតម្រូវឯកសារសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម ដោយអនុលោមតាមប្រកាសនេះ។ សំណុំឯកសារនឹងត្រូវបង្វិលឲ្យអ្នកស្នើសុំវិញ ក្នុងករណីនាយកដ្ឋាននីតិកម្មកសិកម្មពិនិត្យឃើញថាឯកសារមិនគ្រប់គ្រាន់។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចលើកលែងការតម្រូវទិន្នន័យឬព័ត៌មានណាមួយនៃថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី ក្នុងករណីអ្នកស្នើសុំមានឯកសារប្រភពដើមបង្ហាញនូវទិន្នន័យឬព័ត៌មានទាំងនោះ ដែលបានមកពីការពិសោធសាកល្បងក្រោមលក្ខខណ្ឌកេ្សត្របរិស្ថានដូចគ្នា ឬប្រហាក់ប្រហែលជាមួយនឹងលក្ខខណ្ឌកេ្សត្របរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា។

ការតម្រូវឯកសារស្តីពីទិន្នន័យនិងព័ត៌មានសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ពន្ធទី៤នៃប្រកាសនេះ។

**ប្រការ ១៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិតាមចំនួនយថាប្រភេទថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី នៅពេលដែលសំណុំឯកសារត្រូវបានទទួលយកដោយនាយកដ្ឋាននីតិកម្មកសិកម្មដើម្បីដាក់ឆ្លងដំណើរការពិនិត្យនិងវាយតម្លៃ។

**ប្រការ ២០.-**

សំណុំឯកសារស្នើសុំការចុះបញ្ជីថ្នាំកសិកម្មដែលបានបំពេញគ្រប់គ្រាន់ និងភ្ជាប់ជាមួយប័ណ្ណចំណូលកម្រៃសេវាកម្ម ត្រូវបានបញ្ចូលក្នុងដំណើរការនៃការចុះបញ្ជីដើម្បីពិនិត្យវាយតម្លៃលើការតម្រូវបមាណីយ។

ដំណើរការពិនិត្យវាយតម្លៃមិនបានរាប់បញ្ចូលនូវរយៈពេលបន្ថែមដែលត្រូវបង្វែរឲ្យបំពេញឯកសារឡើងវិញក្នុងករណីទិន្នន័យមិនគ្រប់គ្រាន់ឬមិនច្បាស់លាស់ ដោយអនុលោមតាមការតម្រូវបមាណីយដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងនីតិវិធីនៃប្រកាសនេះ។

ការពិនិត្យនិងវាយតម្លៃលើសំណុំឯកសារស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ត្រូវបានសំយោគដោយនាយកដ្ឋាននីតិកម្មកសិកម្ម និងត្រូវបញ្ជូនដើម្បីស្នើសុំការពិនិត្យសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អ្នកស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម អាចទទួលព័ត៌មានស្តីពីលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីនៅនាយកដ្ឋាននីតិកម្មកសិកម្ម ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលយកសំណុំឯកសារគ្រប់គ្រាន់។

គំនូសបំព្រួញស្តីពីដំណើរការនៃការចុះបញ្ជីថ្នាំកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

**ប្រការ ២១.-**

វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្មដែលចេញដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាន២(ពីរ)ប្រភេទ៖

១- បញ្ជិកាពេញលេញ៖ ត្រូវបានផ្តល់ក្នុងករណីការតម្រូវផ្នែកបច្ចេកទេស ទិន្នន័យពាក់ព័ន្ធជីវប្រសិទ្ធភាព សុវត្ថិភាពចំពោះបរិស្ថាន និងសុវត្ថិភាពចំពោះមនុស្ស ត្រូវបានបំពេញគ្រប់គ្រាន់ដោយអនុលោមតាមការតម្រូវបមាណីយដូចមានចែងក្នុងប្រកាសនេះ។ វិញ្ញាបនបត្របញ្ជាក់បញ្ជិកាពេញលេញនៃថ្នាំកសិកម្មមានសុពលភាព៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកានោះ។

២- បញ្ជិកាបណ្តោះអាសន្នឬបញ្ជិកាស្ថិតក្នុងលក្ខខណ្ឌ៖ ត្រូវបានផ្តល់ក្នុងករណីការតម្រូវផ្នែកបច្ចេកទេសត្រូវបានបំពេញ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ស្របតាមការតម្រូវបមាណីយឬព័ត៌មានមិនច្បាស់លាស់ ជាពិសេសព័ត៌មានពាក់ព័ន្ធជីវប្រសិទ្ធភាពនៃប្រភេទថ្នាំកសិកម្មនោះ។ វិញ្ញាបនបត្របញ្ជាក់បញ្ជិកាបណ្តោះអាសន្ននៃថ្នាំកសិកម្ម មានសុពលភាព១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលចេញ

វិញ្ញាបនបត្របញ្ជាក់បញ្ជិកានោះ។

បញ្ជិកាបណ្តោះអាសន្នអាចផ្ទេរទៅជាបញ្ជិកាពេញលេញក្នុងរយៈពេល១(មួយ)ឆ្នាំ នៅពេលដែលអ្នកស្នើសុំបានបំពេញតាមការតម្រូវបមាណីយគ្រប់គ្រាន់ ដោយអនុលោមតាមប្រកាសនេះ។

គំរូវិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៦នៃប្រកាសនេះ។

**ប្រការ ២២.-**

ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាពនៃបញ្ជិកាពេញលេញឬបញ្ជិកាបណ្តោះអាសន្ន សិទ្ធិវន្តលើបញ្ជិកាថ្នាំកសិកម្មត្រូវស្នើសុំការចុះបញ្ជីជាថ្មីនូវផលិតផលរបស់ខ្លួន ដោយត្រូវបំពេញពាក្យស្នើសុំ និងការតម្រូវស្របតាមនីតិវិធីនៃប្រកាសនេះ។

ក្នុងករណីគ្មានសំណើសុំការចុះបញ្ជីជាថ្មី បញ្ជិកាពេញលេញឬបញ្ជិកាបណ្តោះអាសន្ននៃប្រភេទថ្នាំកសិកម្មនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិនៅកាលបរិច្ឆេទផុតសុពលភាពដូចបានកំណត់នៅលើវិញ្ញាបនបត្របញ្ជាក់បញ្ជិកានោះ។

**ប្រការ ២៣.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុញ្ញាតបន្តសុពលភាពបញ្ជិកាបណ្តោះអាសន្នថ្នាំកសិកម្មតែមួយលើកគត់ក្នុងរយៈពេល១(មួយ)ឆ្នាំ។ នៅកាលបរិច្ឆេទផុតសុពលភាពបន្ត ក្នុងករណីអ្នកស្នើសុំនៅតែមិនអាចបំពេញគ្រប់គ្រាន់តាមការតម្រូវបមាណីយ បញ្ជិកាបណ្តោះអាសន្ននោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាបណ្តោះអាសន្នថ្នាំកសិកម្ម មិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ប៉ុន្តែសិទ្ធិវន្តឬអ្នកកាន់កាប់បញ្ជិកាបណ្តោះអាសន្ន អាចធ្វើការពិសោធសាកល្បងលើទីវាលពិសោធន៍បន្ថែមទៀតលើប្រភេទថ្នាំកសិកម្មនោះ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ២៤.-**

រាល់ផលិតផលថ្នាំកសិកម្មដែលខកខានក្នុងការស្នើសុំការចុះបញ្ជីជាថ្មីនៅមុនកាលបរិច្ឆេទផុតសុពលភាព ត្រូវចាត់ទុកជាថ្នាំកសិកម្មថ្មីដែលត្រូវពិនិត្យវាយតម្លៃស្របតាមដំណើរការនៃការចុះបញ្ជីដូចមានចែងក្នុងប្រកាសនេះ។

ថ្នាំកសិកម្មគ្រប់ប្រភេទដែលផុតសុពលភាពបញ្ជិកាដោយមិនបានសុំការចុះបញ្ជីជាថ្មី មិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មឬធ្វើចរាចរណ៍លើទីផ្សារបានឡើយ ហើយត្រូវប្រមូលមកវិញក្រោមបន្ទុករបស់សិទ្ធិវន្តលើបញ្ជិកានោះក្នុងរយៈពេល៦(ប្រាំមួយ)ខែគិតចាប់ពីថ្ងៃផុតសុពលភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជាថ្មីថ្នាំកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ២៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជាថ្មីនូវថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

១- ក្នុងករណីមានការផ្លាស់ប្តូរទិន្នន័យណាមួយដែលបានអះអាងនៅពេលសុំការចុះបញ្ជីលើកមុន ត្រូវផ្តល់ព័ត៌មាននិងទិន្នន័យបន្ថែម ឬភ្ជាប់ព្រឹត្តបត្រព័ត៌មានសុវត្ថិភាពជាមួយសំណុំបែបបទស្នើសុំការចុះបញ្ជីជាថ្មី ដូចមានចែងក្នុងប្រការ៨នៃប្រកាសនេះ។

២- ផ្តល់លទ្ធផលវិភាគចុងក្រោយបំផុតលើសមាសធាតុនៃប្រភេទថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជីជាថ្មី ដែលចេញដោយមន្ទីរពិសោធន៍ជាតិកសិកម្មឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ២៦.-**

ការផ្ទេរសិទ្ធិលើបញ្ជិកាថ្នាំកសិកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអ្នកស្នើសុំត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ក្នុងករណីបញ្ជិកាដើមដែលស្នើសុំផ្ទេរសិទ្ធិនៅមានសុពលភាពតែក្នុងរយៈពេល៣(បី)ខែ ការផ្ទេរសិទ្ធិត្រូវប្រព្រឹត្តទៅក្រោមការស្នើសុំការចុះបញ្ជីជាថ្មីក្រោមបន្ទុករបស់អ្នកកាន់កាប់បញ្ជិកាដើម។

២- ត្រូវផ្តល់ព័ត៌មានអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ថ្មី។

៣- ត្រូវបង់កម្រៃសេវាកម្មលើការចុះបញ្ជីជាថ្មី។

៤- ត្រូវធានាបមាណីយគុណភាពនៃសារធាតុសកម្មថ្នាំកសិកម្មតាមការអះអាងក្នុងបញ្ជិកាដើមដែលត្រូវផ្ទេរសិទ្ធិ។

៥- ត្រូវទទួលខុសត្រូវលើរាល់កាតព្វកិច្ចពាក់ព័ន្ធក្នុងការកាន់កាប់បញ្ជិកាថ្នាំកសិកម្ម។

**ប្រការ ២៧.-**

នាយកដ្ឋាននីតិកម្មកសិកម្មត្រូវធ្វើសម្រង់បញ្ជីថ្នាំកសិកម្មដែលបានផ្តល់បញ្ជិកាអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានភារកិច្ចតាមដាននិងធ្វើបច្ចុប្បន្នភាពនៅរៀងរាល់ឆ្នាំ ដើម្បីធ្វើអធិការកិច្ចចរាចរណ៍ថ្នាំកសិកម្មលើទីផ្សារ និងដើម្បីចាត់វិធានការឃ្រេញការអនុវត្តច្បាប់។

## ជំពូកទី ៥
## ការការពារសិទ្ធិលើទិន្នន័យ

**ប្រការ ២៨.-**

បន្ថែមលើការតម្រូវធ្វើវិភាគនិងការពិសោធសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម អាចស្នើសុំធ្វើការសាកល្បងលើទីវាលពិសោធន៍ជាក់លាក់

បន្ថែម ដោយអនុវត្តចំពោះប្រភេទដំណាំឬក្រុមប្រភេទដំណាំ ប្រភេទសមាសភាពចង្រៃ នៅតំបន់សាកល្បងផ្សេងៗគ្នា ដើម្បីបង្កើតទិន្នន័យជីវប្រសិទ្ធភាពថ្មីបន្ថែមនៃប្រភេទថ្នាំកសិកម្មនោះ។

**ប្រការ ២៩.-**

រាល់ទិន្នន័យជីវប្រសិទ្ធភាពថ្មីនៃថ្នាំកសិកម្មដែលបានពិសោធសាកល្បងលើទីវាលពិសោធន៍សម្រាប់ ស្នើសុំការចុះបញ្ជីថ្នាំកសិកម្មនោះនៅគ្រាដំបូង ត្រូវបានផ្តល់ការការពារសិទ្ធិលើទិន្នន័យពិសោធសាកល្បងជីវប្រសិទ្ធភាពនោះក្នុងរយៈពេល៨(ប្រាំបី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកា តាមការស្នើសុំរបស់អ្នកស្នើសុំការចុះបញ្ជី។

**ប្រការ ៣០.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីប្រភេទថ្នាំកសិកម្មដូចគ្នា និងមានប្រភពដើមលាយផ្សំដូចគ្នា អាចស្នើសុំការអនុញ្ញាតពីភាគីដែលកាន់កាប់សិទ្ធិលើបញ្ជិកានិងសិទ្ធិលើទិន្នន័យពិសោធសាកល្បងជីវប្រសិទ្ធភាពថ្មី ដើម្បីប្រើប្រាស់ទិន្នន័យជីវប្រសិទ្ធភាពថ្មីនោះសម្រាប់ការចុះបញ្ជីថ្នាំកសិកម្មរបស់ខ្លួន។ ក្នុងករណីគ្មានការអនុញ្ញាតពីភាគីដែលកាន់កាប់សិទ្ធិលើទិន្នន័យ រូបវន្តបុគ្គលឬនីតិបុគ្គលនោះត្រូវប្រើប្រាស់ទិន្នន័យពិសោធសាកល្បងជីវប្រសិទ្ធភាពថ្មីរបស់ខ្លួនដែលស្នើសុំបង្កើតស្របតាមនីតិវិធីនៃប្រកាសនេះ ឬត្រូវប្រើទិន្នន័យពិសោធសាកល្បងជីវប្រសិទ្ធភាពតាមការតម្រូវ ដែលចេញដោយស្ថានីយពិសោធន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ផុតរយៈពេល៨(ប្រាំបី)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកា រាល់ទិន្នន័យជីវប្រសិទ្ធភាពដែលពាក់ព័ន្ធ អាចប្រើប្រាស់ជំនួសក្នុងការស្នើសុំការចុះបញ្ជីថ្នាំកសិកម្មដែលមានប្រភេទដូចគ្នា និងមានប្រភពដើមលាយផ្សំដូចគ្នា។

## ជំពូកទី ៦
## ការត្រួតពិនិត្យបញ្ញាណីយសម្រាប់ស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម

**ប្រការ ៣១.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីថ្នាំកសិកម្ម ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម នូវគំរូស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម ដើម្បីស្នើសុំការពិនិត្យ វាយតម្លៃ ឬកែតម្រូវជាមុនដោយនាយកដ្ឋាននីតិកម្មកសិកម្ម។

គំរូស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្មដែលប្រើប្រាស់នៅលើឬភ្ជាប់ជាមួយសំបកវេចខ្ចប់ថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវមានការយល់ព្រមជាមុនពីនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងដំណើរការនៃការចុះបញ្ជីថ្នាំកសិកម្មនោះ។

**ប្រការ ៣២.-**

រាល់ស្លាកសញ្ញាព័ត៌មានរបស់ថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវតែមានជាភាសាខ្មែរ និងត្រូវភ្ជាប់ជាមួយឬបោះពុម្ពនៅលើផ្ទៃនៃសំបកវេចខ្ចប់ក្នុងលក្ខណៈដែលព័ត៌មានទាំងអស់នៃស្លាកសញ្ញា អាចមើលឃើញ អានបាន ងាយយល់ និងមិនងាយលុប។

គោលការណ៍ណែនាំសម្រាប់ស្លាកសញ្ញាព័ត៌មាននិងគំរូស្លាកសញ្ញាព័ត៌មាននៃថ្នាំកសិកម្មត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី ៧
## ទិន្នន័យថាប្រភេទថ្នាំកសិកម្ម

**ប្រការ ៣៣.-**

ទិន្នន័យថាប្រភេទថ្នាំកសិកម្មមានសារសំខាន់ក្នុងការធានាចំពោះប្រភេទណាមួយនៃផលិតផលថ្នាំកសិកម្ម ដែលលាយផ្សំឡើងដោយប្រើប្រាស់សារធាតុគីមីណាមួយ ត្រូវមានភាពដូចគ្នាទៅនឹងទិន្នន័យដែលស្នើសុំការចុះបញ្ជី និងធានានូវកម្រិតភាពសុទ្ធនៃសារធាតុសកម្មថ្នាំកសិកម្ម ដែលត្រូវធ្វើអត្តសញ្ញាណនិងវាយតម្លៃក្នុងការចុះបញ្ជី។

រាល់ទិន្នន័យថាប្រភេទ ត្រូវឆ្លើយតបតាមការតម្រូវគីមីសាស្ត្រនៃផលិតផល រួមមានសេចក្តីអធិប្បាយអំពីដំណើរការលាយផ្សំនៃសារធាតុសកម្ម ព័ត៌មានស្តីពីសមាសធាតុនៃផលិតផល លក្ខណៈរូបសាស្ត្រ និងលក្ខណៈគីមីសាស្ត្រនៃថ្នាំកសិកម្ម ។

**ប្រការ ៣៤.-**

ព័ត៌មានស្តីពីសមាសធាតុនៃថ្នាំកសិកម្ម រួមមានព័ត៌មាននៃគ្រប់សារធាតុសកម្ម សារធាតុនិចលដំណើរការលាយផ្សំ ទិន្នន័យស្តីពីភាពសុទ្ធ លទ្ធផលវិភាគបឋមនៃសំណាកថ្នាំកសិកម្ម ទិន្នន័យកម្រិតអនុគ្រោះនៃសារធាតុសកម្ម និងវិធីសាស្ត្រវិភាគ មានសារសំខាន់ក្នុងការកំណត់អត្តសញ្ញាណ និងបរិមាណនៃសារធាតុសកម្ម ជាពិសេសក្នុងករណីកម្រិតលើសពី0.1% ដែលអាចប្រកាសនូវភាពពុលនៃផលិតផល។

**ប្រការ ៣៥.-**

ទិន្នន័យថាប្រភេទថ្នាំកសិកម្ម ត្រូវមានសង្គតិភាពជាមួយគំរូការតម្រូវទិន្នន័យដែលកំណត់ដោយអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO) និងអង្គការសុខភាពពិភពលោក(WHO)។

បមាណីយអនុគ្រោះសម្រាប់ផលិតផលថ្នាំកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៧នៃប្រកាសនេះ។

# ជំពូកទី ៨
# ការចុះបញ្ជីថ្នាំកសិកម្ម
# សម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម

**ប្រការ ៣៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលថ្នាំកសិកម្មសម្រាប់តម្រូវការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម រួមមានតម្រូវការសាធារណៈក្នុងវិស័យសិក្សាធិការ ការស្រាវជ្រាវ វិស័យសុខាភិបាល ការធ្វើអំណោយដល់សាធារណៈ ការតាំងពិព័រណ៍ផ្លូវការ ឬសម្រាប់តម្រូវការប្រើប្រាស់ចុងក្រោយផ្សេងទៀតដែលមិនមែនជាការធ្វើពាណិជ្ជកម្មឬចរាចរណ៍លើទីផ្សារ ត្រូវស្នើសុំការចុះបញ្ជីនិងលិខិតអនុញ្ញាតនាំចូលនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣៧.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុគ្រោះចំពោះការសុំចុះបញ្ជីថ្នាំកសិកម្មសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម ដែលពុំមានព័ត៌មានគ្រប់គ្រាន់ស្របតាមការតម្រូវបមាណីយ ប៉ុន្តែចាំបាច់ត្រូវផ្តល់ឯកសារស្តីពីយថាប្រភេទនៃថ្នាំកសិកម្ម រួមមាន៖

- ឈ្មោះពាណិជ្ជកម្ម ឬឈ្មោះទូទៅនៃប្រភេទថ្នាំកសិកម្ម
- លេខកូដសម្គាល់សារធាតុសកម្មនៃប្រភេទថ្នាំកសិកម្ម (CAS.Number)
- ឈ្មោះប្រទេសប្រភពដើមផលិតឬនាំចូលមកកម្ពុជា
- មុខសញ្ញាប្រើប្រាស់និងបរិមាណប្រើប្រាស់ដែលត្រូវស្នើសុំនាំចូល។

ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចផ្តល់បញ្ជិកាបណ្តោះអាសន្នថ្នាំកសិកម្មនោះ សម្រាប់តែតម្រូវការប្រើប្រាស់ជាក់លាក់ក្នុងសុពលភាពរយៈពេល១(មួយ)ឆ្នាំប៉ុណ្ណោះ។

**ប្រការ ៣៨.-**

ថ្នាំកសិកម្មដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុញ្ញាតឲ្យនាំចូលសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម មិនអាចធ្វើចរាចរណ៍លើទីផ្សារ ឬធ្វើការផ្គត់ផ្គង់ចែកចាយជាលក្ខណៈពាណិជ្ជកម្ម និងធ្វើការផ្សាយពាណិជ្ជកម្មបានឡើយ។

ការប្រព្រឹត្តល្មើសនឹងប្រការនេះ នឹងត្រូវផ្តន្ទាទោសដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី ៩
## ភារកិច្ចអ្នកកាន់កាប់បញ្ជិកាថ្នាំកសិកម្ម

**ប្រការ ៣៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលកាន់កាប់បញ្ជិកាពេញលេញឬបញ្ជិកាបណ្តោះអាសន្ន ដើម្បីប្រើប្រាស់ក្នុងគោលបំណងឬក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវមានសៀវភៅកំណត់ត្រាអំពីការកាន់កាប់ថ្នាំកសិកម្មរបស់ខ្លួន និងមានកាតព្វកិច្ចធ្វើរបាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរៀងរាល់ត្រីមាស និងប្រចាំឆ្នាំ។

របាយការណ៍របស់អ្នកកាន់កាប់បញ្ជិកាថ្នាំកសិកម្ម ត្រូវផ្តល់ព័ត៌មានដូចខាងក្រោម៖

- ផលប៉ះពាល់ឬគ្រោះថ្នាក់ដែលបានកើតឡើងនៅក្នុងប្រតិបត្តិការពាណិជ្ជកម្ម ឬការប្រើប្រាស់ប្រភេទថ្នាំកសិកម្មនោះតាមការណែនាំក្នុងស្លាកសញ្ញាព័ត៌មានដែលបានអះអាង នៅពេលស្នើសុំការចុះបញ្ជី
- ចំនួនឧបទ្ទវហេតុគ្រោះថ្នាក់ដែលបានកើតឡើង ដោយកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ ទីកន្លែងប្រើប្រាស់ ប្រភេទថ្នាំកសិកម្មនិងកម្រិតប្រើប្រាស់
- សេចក្តីសន្និដ្ឋានលើផលប៉ះពាល់ឬឧបទ្ទវហេតុនីមួយៗ និងលទ្ធផលចុងក្រោយ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**ប្រការ ៤០.-**

រូបវន្តបុគ្គលឬនីតិបុគ្គលណាដែលប្រព្រឹត្តល្មើស ឬមិនគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះត្រូវទទួលទណ្ឌកម្មជាក់លាក់ ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៤១.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤២.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កក ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

ច័ន្ទ សារុន

**កន្លែងទទួល៖**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- -ក្រសួងយុត្តិធម៌
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -សាលារាជធានី ខេត្ត
- -ដូចប្រការ ៤២
- -ឯកសារ កាលប្បវត្តិ

ឧបសម្ពន្ធទី១ នៃប្រកាសលេខ.៤៥៦.......ប្រក.កសក ចុះថ្ងៃទី១៩.ខែតុលា.ឆ្នាំ២០១២
"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម"

# ប្រភេទថ្នាំកសិកម្មតាមចំណាត់ថ្នាក់

សម្រាប់គោលបំណងនៃការចុះបញ្ជី ថ្នាំកសិកម្មត្រូវបានចាត់ថ្នាក់ជាក្រុមដោយផ្អែកតាមលក្ខណៈនៃសមាសធាតុនិងមុខសញ្ញាប្រើប្រាស់ដូចខាងក្រោម៖

## I.ថ្នាំកសិកម្មគីមី

### ក-ថ្នាំកសិកម្មប្រើប្រាស់ក្នុងផលិតកម្មកសិកម្មនិងសួនគេហដ្ឋាន

(Agricultural and Home Garden Use) រួមមាន៖

១-ថ្នាំកម្ចាត់សត្វល្អិត(Insecticide)

២-ថ្នាំកម្ចាត់ផ្សិត (Fungicide)

៣-ថ្នាំកម្ចាត់ស្មៅ (Herbicide)

៤-ថ្នាំកម្ចាត់សត្វកកេរ(Rodenticide)

៥-ថ្នាំកម្ចាត់សត្វស្លាប(Avicide)

៦-ថ្នាំកម្ចាត់ណេម៉ាតូត(Nematicide)

៧-ថ្នាំកម្ចាត់បាក់តេរី(Bactericide)

៨-ថ្នាំកម្ចាត់សត្វខ្យង(Molluscicide)

៩-ថ្នាំកម្ចាត់សត្វចៃ សង្កើច(Acaricide/ Miticide)

១០-ថ្នាំកម្ចាត់វារីសត្វ(Piscicide)។

### ខ-ថ្នាំកសិកម្មប្រើប្រាស់ក្នុងលំនៅឋាន និងសម្រាប់សុខភាពសាធារណៈ

(Household and Public Health Use )រួមមាន៖

១-ថ្នាំកម្ចាត់សត្វល្អិត (Insecticide)

២-ថ្នាំកម្ចាត់សត្វកណ្តៀរឬស្រមោច (Termicide)

៣-ថ្នាំកម្ចាត់សត្វកកេរ (Rodenticide)។

### គ-ថ្នាំកសិកម្មគីមីផ្សេងទៀត(Other chemical pesticides)

១-ថ្នាំការពារឈើ(Wood preservative)

២-ថ្នាំនិយតករឬជំរុញការលូតលាស់នៃដំណាំ(Plant Growth regulator / Promotor)

៣-ថ្នាំជម្រុះស្លឹក(Defoliant)

៤-ថ្នាំក្រីមែក(Desiccant)

៥-សារធាតុនិចលនៃថ្នាំកសិកម្ម(Activator of resistance, Surfactant, Adjuvant, Emulsifier, Welling agent, Penetrant synergist)

៦-ផលិតផលពាក់កណ្តាលសម្រេចនៃថ្នាំកសិកម្ម។

## II.ថ្នាំកសិកម្មជីវសាស្ត្រ (Biorational Pesticides)

### ក-ភ្នាក់ងារកម្ចាត់សមាសភាពចង្រៃជីវគីមី (Biochemical pest control agents)

១-Semiochemical : Pheromone/ Kairomone/ allomone

២-Hormone

៣-Phytohormone "Auxin" ។

### ខ-ភ្នាក់ងារកម្ចាត់សមាសភាពចង្រៃមីក្រូជីវសាស្ត្រ (Microbial pest control agents)

១-Bacterium

២-Fungus

៣-Protozoa

៤-Virus។

ឧបសម្ពន្ធទី២ នៃប្រកាសលេខ..២៤៦........ប្រក.កសក ចុះថ្ងៃទី១៩..ខែតុលា.ឆ្នាំ២០១២

"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម"

# សេចក្តីអធិប្បាយព័ត៌មាននិងទិន្នន័យស្តីពីថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី

CLARIFICATION ON INFORMATION AND DATA FOR THE APPLICATION OF PESTICIDES REGISTRATION

| **អត្តសញ្ញាណនៃសារធាតុសកម្មរូបធាតុបច្ចេកទេស (TG/TC) ផលិតផលថ្នាំកសិកម្មលាយផ្សំ (FPP)** | | |
|---|---|---|
| ១. | ឈ្មោះគីមីនៃសារធាតុសកម្មរូបធាតុបច្ចេកទេស និងផលិតផលថ្នាំកសិកម្មលាយផ្សំ(TG/TC/FPP) | |
| ២. | ឈ្មោះពាណិជ្ជកម្មនៃផលិតផលថ្នាំកសិកម្មលាយផ្សំ (FPP) | |
| ៣. | ទម្រង់ផ្សំ ភាគរយនៃសារធាតុសកម្ម | |

| **ចំណាត់ថ្នាក់ភាពពុលគីមី (ចំណាត់ថ្នាក់ WHO) "គូសក្នុងប្រអប់"** | |
|---|---|
| | WHO (Class I a) - Extremely hazardous |
| | WHO (Class I b) - Highly hazardous |
| | WHO (Class II) - Moderately hazardous |
| | WHO (Class III) - Slightly hazardous |
| | (U) – Unlikely hazardous |
| | ចំណាត់ថ្នាក់ផ្សេងទៀត (UNEP-PIC/POP) |

| **ចំណាត់ថ្នាក់នៃថ្នាំកសិកម្ម "គូសក្នុងប្រអប់"** | | | | | |
|---|---|---|---|---|---|
| | ថ្នាំកម្ចាត់សត្វល្អិត (Insecticide) | | ថ្នាំកម្ចាត់បាក់តេរី (Bactericide) | | ថ្នាំនិយ័តករការលូតលាស់នៃដំណាំ(PGR) |
| | ថ្នាំកម្ចាត់ផ្សិត (Fungicide) | | ថ្នាំកម្ចាត់សត្វខ្យង (Molluscicide) | | ថ្នាំជម្រុះស្លឹក (Defoliant) |
| | ថ្នាំកម្ចាត់ស្មៅ (Herbicide) | | ថ្នាំកម្ចាត់សត្វចៃសង្កើច (Acaricide/ Miticide) | | ថ្នាំក្រៀមែក (Desiccant) |
| | ថ្នាំកម្ចាត់សត្វកកេរ (Rodenticide) | | ថ្នាំកម្ចាត់វារីសត្វ (Piscicide) | | Pheromone |
| | ថ្នាំកម្ចាត់សត្វស្លាប (Avicide) | | ថ្នាំកម្ចាត់សត្វកណ្ដៀរឬស្រមោច (Termicide) | | Hormone |
| | ថ្នាំកម្ចាត់ណេម៉ាតូត (Nematicide) | | ថ្នាំការពារឈើ (Wood preservative) | | |
| | ថ្នាំកសិកម្មផ្សេងទៀត (បញ្ជាក់ចំណាត់ថ្នាក់) | | | | |

| គោលចំណាត់ប្រើប្រាស់ថ្នាំកសិកម្ម "គួសក្នុងប្រអប់" | | | |
|---|---|---|---|
| | ចំណាត់ថ្នាក់ប្រើប្រាស់ (Use categories) | | មុខសញ្ញាប្រើប្រាស់ (Use partterns) |
| | ប្រើលើដីគោក (Terrestrial) | | ប្រើចំពោះផលិតផលស្បៀងលើដីគោក |
| | | | ប្រើចំពោះចំណីសត្វលើដីគោក |
| | | | ប្រើចំពោះផលិតផលក្រៅពីស្បៀងលើដីគោក |
| | ប្រើក្នុងទឹក (Aquatic) | | ប្រើចំពោះផលិតផលស្បៀងក្នុងទឹក |
| | | | ប្រើចំពោះផលិតផលក្រៅពីស្បៀងក្នុងទឹក |
| | ប្រើក្នុងផ្ទះកញ្ចក់ (Green house) | | ប្រើចំពោះផលិតផលស្បៀងក្នុងផ្ទះកញ្ចក់ |
| | | | ប្រើចំពោះផលិតផលក្រៅពីស្បៀងក្នុងផ្ទះកញ្ចក់ |
| | ប្រើក្នុងរុក្ខវប្បកម្ម ការដាំឈើ (Forestry/Plantation) | | ប្រើចំពោះផល អនុផលព្រៃឈើ |
| | | | ប្រើចំពោះផលិតផលស្បៀងនៃចំការព្រៃឈើ |
| | | | ប្រើចំពោះផលិតផលក្រៅពីស្បៀងនៃចំការព្រៃឈើ |
| | ក្រៅលំនៅដ្ឋាន (Residential "Outdoor") | | ប្រើក្រៅលំនៅដ្ឋាន |
| | ក្នុងលំនៅដ្ឋាន (Indoor) | | ប្រើក្នុងលំនៅដ្ឋាន |
| | | | ប្រើចំពោះផលិតផលក្រៅពីស្បៀងនៅក្នុងលំនៅដ្ឋាន ឬមិនមែនលំនៅដ្ឋាន |
| | | | ប្រើចំពោះផលិតផលស្បៀងនៅក្នុងលំនៅដ្ឋាន |
| | ការប្រើប្រាស់ដោយផ្ទាល់លើមនុស្ស ឬសត្វ (Direct Application on Humans /Animals) | | ការប្រើប្រាស់ដោយផ្ទាល់ចំពោះមនុស្ស ឬសត្វ |

| ការតម្រូវព័ត៌មាន និងទិន្នន័យសម្រាប់ការចុះបញ្ជី ភាពអនុលោម (Registration data requirements/Compliance with) "គួសក្នុងប្រអប់" | | | |
|---|---|---|---|
| ការតម្រូវព័ត៌មាន និងទិន្នន័យសម្រាប់ការចុះបញ្ជី (Registration data requirements) | | អនុលោមជាមួយ (Compliance with) | |
| | កម្រង "ក" ៖ ទិន្នន័យរូប-គីមី | | អនុលោមជាមួយ |
| | កម្រង "ខ" ៖ ទិន្នន័យស្តីពីភាពពុល | | អនុលោមជាមួយ |
| | កម្រង "គ" ៖ ទិន្នន័យសាកល្បងជីវប្រសិទ្ធភាព | | អនុលោមជាមួយ |
| | កម្រង "ឃ" ៖ ទិន្នន័យស្តីពីសំណល់ថ្នាំកសិកម្ម | | អនុលោមជាមួយ |
| | កម្រង "ង" ៖ ទិន្នន័យស្តីពីភាពប្រឈមចំពោះសុខភាពមនុស្ស និងបរិស្ថាន | | អនុលោមជាមួយ |

| | | | |
|---|---|---|---|
| | កម្រង "ច" ៖ ទិន្នន័យស្ដីពីស្លាកសញ្ញាព័ត៌មាន ការវេចខ្ចប់ និងការធ្វើសន្និធិ | | អនុលោមជាមួយ |
| | កម្រង "ឆ" ៖ ឯកសារផ្សេងទៀតត្រូវភ្ជាប់ | | អនុលោមជាមួយ |

**ការផ្ដល់យោបល់ក្នុងករណីមានព័ត៌មាននិងទិន្នន័យណាមួយមិនអនុលោមជាមួយ**

**ព័ត៌មានបន្ថែម** (Additional information)

| | |
|---|---|
| លិខិតប្រគល់សិទ្ធិដើម្បីប្រើប្រាស់ទិន្នន័យដែលចេញដោយអ្នកកាន់កាប់បញ្ជិកាដើម (ក្នុងករណីផ្ទេរសិទ្ធិបញ្ជិកា ឬសិទ្ធិលើទិន្នន័យ) | |

**សេចក្ដីបញ្ជាក់អះអាង** (Clarification/Declaration)

ខ្ញុំបាទ នាងខ្ញុំ.......................................សូមបញ្ជាក់ អះអាងដោយស្មោះត្រង់តាមការយល់ដឹង និងការជឿជាក់របស់ខ្ញុំថា ព័ត៌មាននិងទិន្នន័យដែលបានផ្ដល់ ព្រមទាំងឯកសារជូនភ្ជាប់ទាំងអស់សម្រាប់ស្នើសុំការចុះបញ្ជីថ្នាំកសិកម្មខាងលើពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់។

ដើម្បីជាសក្ខីភាព ពេលនេះខ្ញុំសូមចុះហត្ថលេខាជាភស្តុតាងនៅទីកន្លែង និងកាលបរិច្ឆេទដូចខាងក្រោម៖

ទីកន្លែង៖.........................................

**ហត្ថលេខានិងឈ្មោះប្រធានក្រុមហ៊ុន និងត្រាក្រុមហ៊ុន**

កាលបរិច្ឆេទ៖ ថ្ងៃទី ខែ ឆ្នាំ

**កំណត់សម្គាល់:**

- TG : Technical grade
- TC : Technical Concentration
- FPP : Formulated Pesticide Product
- WHO : World Health Organization
- UNEP : United Nation Of Enviroment Protection
- PIC : Prior Informed Concent
- POP : Persistent Oganic Pollutant

ឧបសម្ពន្ធទី៣ នៃប្រកាសលេខ.៤៥៤..........ប្រក.កសក ចុះថ្ងៃទី១៩..ខែតុលា..ឆ្នាំ២០១២
"ស្តីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម"

# ពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការពិសោធសាកល្បងជីវប្រសិទ្ធភាពថ្នាំកសិកម្ម

THE APPLICATION FOR REGISTRATION, ANLYSIS & BIO-EFFECACY EXPERIMENTAL TEST OF PESTICIDE

| | | | |
|---|---|---|---|
| **I. ព័ត៌មានទូទៅស្តីពីអ្នកស្នើសុំ** (General Information on the Applicant) | | | |
| ១-ឈ្មោះអ្នកស្នើសុំ ៖ | | | |
| ២-សញ្ជាតិ៖ | | ភេទ ៖ | |
| ៣-អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ៖ | | ផុតកំណត់ថ្ងៃទី៖ | |
| ៤-ក្រុមហ៊ុនឬនីតិបុគ្គលឯកជន៖ "គូសក្នុងប្រអប់" | | | |
| | នាំចូលនាំចេញ | | ផលិតលាយផ្សំ |
| | វេចខ្ចប់ជាថ្មី | | ផ្គត់ផ្គង់ចែកចាយ |
| | សហគមន៍កសិកម្ម | | ក្រុមហ៊ុនវិនិយោគដំណាំកសិឧស្សាហកម្ម |
| | នីតិបុគ្គលឯកជនផ្សេងទៀត (បញ្ជាក់)៖ | | |
| ៥-អាសយដ្ឋាននៅកម្ពុជា៖ | | | |
| ទូរស័ព្ទឬទូរសារ៖ | | | |
| គេហទំព័រ៖ | | | |
| ៦-ចុះបញ្ជីពាណិជ្ជកម្ម៖ | | | |
| ៧-ឃ្លាំងសន្និធិ | | | |
| លេខចុះបញ្ជី និងអាសយដ្ឋាន | | | |
| | | | |
| | | | |
| ៨-វិញ្ញាបនបត្រពីក្រុមហ៊ុនមេ "បើសិនជាមាន" | | | |
| ៩-អត្តសញ្ញាណនៃអ្នកផលិតលាយផ្សំឬអ្នកផ្គត់ផ្គង់ | | | |
| ឈ្មោះអ្នកផលិតលាយផ្សំ និងអាសយដ្ឋាននៃគ្រឹះស្ថានផលិតលាយផ្សំ (ករណីផលិតកម្មក្នុងស្រុក) | | | |

| | |
|---|---|
| លិខិតអនុញ្ញាតប្រតិបត្តិការផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី (ករណីផលិតកម្មក្នុងស្រុក) | |
| ឈ្មោះនិងអាសយដ្ឋាននៃក្រុមហ៊ុនផ្គត់ផ្គង់ចែកចាយ (សម្រាប់ការនាំចូលនូវផលិតផលថ្នាំកសិកម្មលាយផ្សំ ឬ រូបធាតុបច្ចេកទេស) | |
| លេខបញ្ជិកា និងប្រទេសប្រភពដើមដែលផ្តល់បញ្ជិកា (សម្រាប់ការនាំចូលរូបធាតុបច្ចេកទេស ឬផលិតផលថ្នាំកសិកម្មលាយផ្សំ) | |

## II. គោលបំណងនៃការស្នើសុំ (Purpose and state of registration)

| | | | |
|---|---|---|---|
| | សម្រាប់គោលបំណងពាណិជ្ជកម្ម | | សម្រាប់គោលបំណងក្រៅពាណិជ្ជកម្មឬប្រើប្រាស់ជាក់លាក់ |
| | ការធ្វើវិភាគ | | ការពិសោធសាកល្បងជីវប្រសិទ្ធភាព |
| | ការចុះបញ្ជី | | បញ្ជិកាថ្មី |
| | | | បន្តបញ្ជិកាជាថ្មី |
| | | | ផ្ទេរសិទ្ធិលើបញ្ជិកា |

## III. យថាប្រភេទថ្នាំកសិកម្មដែលស្នើសុំការចុះបញ្ជី (Specification of pesticide to be applied for registration)

☐ មានភ្ជាប់ក្នុង CD

| ល.រ No | ឈ្មោះពាណិជ្ជកម្ម (ផលិតផលថ្នាំកសិកម្ម) Trade name | ឈ្មោះទូទៅ (សារធាតុសកម្ម) Common name (Active ingredient) | លេខអត្តសញ្ញាណ Identification Number (CAS N°) | ចំណាត់ថ្នាក់ថ្នាំកសិកម្ម (Pesticide categories) | ប្រទេសប្រភពដើមផលិតឬលាយផ្សំ Country of origin formulated |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
